ក្រសួងអប់រំ យុវជន និង កីឡា

៣ ការស្រាវជ្រាវ និងព័ត៌មាន

បញ្ហាប៉ពាលកម្មកុមារ

ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

វត្ថុបំណង ៖ រកឃើញហេតុការណ៍ និង តួលេខនៃពលកម្ម កុមារ, ដោយរាប់បញ្ចូលទាំងអនុសញ្ញាអន្តរជាតិ ដើម្បីធ្វើការស្រាវជ្រាវស៊ីជម្រៅអំពីប្រភពផ្សេងៗ ក្នុងនោះមានអ៊ីនធើណែតផង ។



លទ្ធផលរំពឹងទុក ៖ ផ្សព្វផ្សាយចំណេះដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់មនុស្ស និងកាន់តែច្បាស់លាស់ថែមទៀតអំពីសិទ្ធិកុមារ ។ ជំរុញការយល់ដឹងអំពីរបៀបដែលពិភពលោកបានភ្ជាប់ការទាក់ទងគ្នាទៅវិញទៅមក និងច្បាប់គ្រប់គ្រង អាកប្បកិរិយាមនុស្សជាតិ ។

ការកំណត់ពេលវេលា

បង្រៀន ៦ ពេល(ម្តង ២ ពេលជាប់គ្នា)

ហេតុផល

យើងរស់នៅក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងពិភពលោកដែលកំពុងតែរីកចម្រើនកាន់តែច្រើនថែមទៀតជារាងរាល់ថ្ងៃ។ ជាការសំខាន់ណាស់សម្រាប់ឱ្យយុវជនយល់ និងទទួលស្គាល់ថាគេទាំងអស់គ្នាជាប់ទាក់ទងជាមួយអ្នកមានវ័យស្មើគ្នារបស់គេក្នុងប្រទេសផ្សេងៗទៀត។ គ្មានអ្វីកើតឡើងឡើយក្នុងសុញ្ញាកាស (vacuum)។ វិបត្តសេដ្ឋកិច្ច សង្គមនិងវិបត្តិបរិស្ថាន ដែលកើតឡើង នៅទីនោះ និងបង្កឱ្យមានប្រតិឃាតក្នុងពិភពលោកទាំងមូល។ កម្លាំងបដិវត្តន៍នៃព័តិមាន និងទូរគមនាគមន៍មិនអាចកើតឡើង ដោយគ្មានឧទាហរណ៍ផ្សព្វផ្សាយឡើយ។ ពិភពលោកកំពុងតែចង្អៀត ហើយមតិដែលថា "ភូមិនៃពិភពលោក" កាន់តែពិតទៅ ។

វត្ថុបំណងជាបឋមនៃម៉ូឌុលទាំងនេះ គឺបង្កើតចំណងទាក់ទងរវាងយុវជនទូទាំងពិភពលោក-ក្នុងកិច្ចអភិវឌ្ឍន៍ ឧស្សាហូបនីយកម្ម ប្រទេស ក្នុងតំបន់ដែលមានជម្លោះ និងតំបន់ដែលមានសន្តិភាព

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

យើងណែនាំឱ្យអ្នកបង្ហាញម៉ូឌុលនេះទៅក្រុមរបស់អ្នកក្នុងដំណាក់ការទំនាក់ទំនងមុនពេលកំណត់ក្នុងដំណើរការប្រព្រឹត្តទៅ ។ គេនឹងផ្តល់ទាំងការហ្វឹកហ្វឺនអំពីតើដឹកនាំការស្រាវជ្រាវដូចម្តេច និងតើមូលដ្ឋានអ្វីសម្រាប់ក្រុមអនុវត្តម៉ូឌុលផ្សេងៗទៀតជាពិសេសម៉ូឌុលសម្ភាសន៍ប្រព័ន្ធផ្សព្វផ្សាយផងដែរ ។ ក្រុមត្រូវការបង្កើតឡើងចំនួនមួយច្បាស់លាស់ដោយសេចក្តីទុកចិត្តមុនគេ និងលំហាត់មួយចំនួនក្នុងម៉ូឌុលនេះនឹងមិនអាចងាយស្រួលដល់យុវជនទេ ពិសេសវិធីធ្វើការរបស់ពួកគេទាំងឡាយ ។

ពលកម្ម លើកុមារនិងកុមារដែលបានទទួលការអប់រំគ្រប់គ្រាន់ ហើយមានបរិយាកាសទំនាក់ទំនងគ្រួសារប្រកបដោយចីរភាព ។

ក្នុងការធ្វើឱ្យសម្រេចកម្មវិធីនេះមានសារៈសំខាន់ណាស់-ធ្វើការទំនាក់ទំនងរវាងយុវជនត្រូវបានពង្រឹងឡើង ហើយ"សាមគ្គីភាព" ក៏កើតមានឡើង និងរីកចម្រើនកាន់តែធំឡើងៗ ។

នេះជាប្រភពព័ត៌មានស្តីពីពលកម្មកុមារដោយដកស្រង់ចេញពីប្រភពផ្សេងៗ ដូចជាអ៊ុនធើណែតជាដើម- ដែលនៅក្នុងនោះគេរកឃើញស្ថិតិ ក្របខ័ណ្ឌត្រឹមត្រូវនៃច្បាប់ សកម្មភាពលុបបំបាត់ពលកម្មកុមារ និងជួយកុមារទាំងឡាយ និងគ្រួសាររបស់គេ យុទ្ធនាការកំពុងដំណើរការ ។ល។ យុវជនគួរតែយល់ដឹងអំពីព័ត៌មាននេះ និងត្រូវតែបានគាំទ្រក្នុងការប្រឹងប្រែងរបស់គេ ដើម្បីឈានទៅប្រើប្រាស់វា ។ ដោយបានផ្តល់ម៉ូឌុលប្រភេទនេះ ក្រុមអ្នកប្រើប្រាស់នឹង ចាប់ផ្តើមបន្ថែមនូវព័ត៌មាន ស្ថិតិ និងករណីសិក្សាពាក់ព័ន្ធនឹងសកម្មភាពរបស់យុវជនដែលចូលរួមក្នុងយុទ្ធនាការលុបបំបាត់ពលកម្មកុមារ ។

យុវជនគួរយល់ថាគេជាប្រជាជនក្នុងសង្គមទាំងមូល ហើយគេចូលចិត្តអ្នកដទៃទៀតក្នុងសង្គម ។ គេបែងចែកគ្នាទទួលខុសត្រូវនូវអ្វីដែលកើតឡើងក្នុងពិភពលោកដែលល្អ អាក្រក់ មិនល្អសោះអង្គើយ ។ ប្រសិនបើសង្គម រង់ចាំ ឱ្យយុវជនទទួលរ៉ាប់រងទទួលបន្ទុករបស់ខ្លួននោះ សង្គមត្រូវតែផ្តល់សម្ភារ ឧបករណ៍ឱ្យយុវជនបានគ្រប់គ្រាន់។ ចំពោះបញ្ហាដ៏សំខាន់នោះម៉ូឌុលនេះមានបំណងផ្តល់ឱ្យយុវជននូវការទទួលខុសត្រូវរៀបចំផលិតម៉ូឌុលផ្សេងទៀត ដែលជាសម្ភារឧបករណ៍សម្រាប់ធ្វើសកម្មភាព។ ម៉ូឌុលនេះមានបំណងពីរ : ជួយយុវជនចាប់បាននូវព័ត៌មានថ្មីៗ និង ជួយពួកគេឱ្យផ្សព្វផ្សាយនឹងពង្រឹងចំណេះដឹងតាមរយៈការធ្វើសម្ភាសន៍ជាមួយសហគមន៍ ។

តាមរយៈការអនុវត្តន៍ម៉ូឌុលនេះ លោកអ្នកអាចជួយក្រុមយុវជនឱ្យយល់ថាពួកគេមិនមែនខំប្រឹងប្រែងតែឯងទេ នៅក្នុងការលុបបំបាត់ពលកម្មកុមារដ៏ស្មុគស្មាញនេះ។ អង្គការជាច្រើនផ្សេងៗទៀត មានក្រុមនិងបុគ្គលធ្វើការពាក់ព័ន្ធនឹងបញ្ហាដ៏ស្រួចស្រាវនេះ។ ម្យ៉ាងទៀតម៉ូឌុលនេះនឹងណែនាំបង្ហាញដល់យុវជននូវអង្គច្បាប់ និងបទ

បញ្ហាដែលត្រូវបានបង្កើតឡើងជាថ្នាក់អន្តរជាតិដើម្បីជួយដល់រដ្ឋាភិបាលក្នុងការលុបបំបាត់ពលកម្មកុមារនេះ ។

ទិដ្ឋភាពមួយដ៏លំបាកបំផុតនៃពលកម្មកុមារដែលយុវជនត្រូវយល់នោះគឺបាតុភូតតែមានដដែលៗទោះបីកិច្ចប្រឹងប្រែងអន្តរជាតិមានបំណងដ៏ល្អបំផុតនៃរដ្ឋាភិបាលមួយចំនួនក៏ដោយចុះ ។ នេះជាហេតុដែលនាំឱ្យយើងទាំងអស់គ្នាមានតួនាទី និងជាហេតុនាំឱ្យមានការគាំទ្រពីជំនាន់មួយទៅជំនាន់មួយទៀត រហូតដល់ពេលណាដែលកុមារទាំងឡាយបានទទួលសេរីភាពដែលការពារពួកគេ និងគុណភាពនៃជីវិតដែលចិញ្ចឹមពួកគេបានល្អ ។

ការរៀបចំ

ក្នុងបរិបទនៃកិច្ចសន្យារបស់សហគមន៍ក្នុងកម្មវិធីនេះ លោកអ្នកគួរទាក់ទងផ្តាល់នឹងដៃគូដែលមានសកម្មានុពលក្នុងតំបន់ ហើយអាចចូលរួមស្រាវជ្រាវកសាងម៉ូឌុលនេះ និងទាក់ទងអ្នកទាំងឡាយណាដែលអាចផ្តល់ព័ត៌មានពិត ។

ដៃគូសម្រាប់ធ្វើសកម្មភាពស្នើឡើងក្នុងម៉ូឌុលនេះ គឺបណ្ណាល័យមូលដ្ឋានរួមទាំងបណ្ណាល័យក្នុងស្ថាប័នអប់រំផង។ ប្រព័ន្ធបណ្ណាល័យក្នុងប្រទេសជាច្រើនមានសារៈសំខាន់កាន់តែខ្លាំងឡើងៗក្នុងសង្គមព័ត៌មានបច្ចុប្បន្ន និងចំណេះដឹងផ្នែកសេដ្ឋកិច្ចបណ្ណាល័យទាំងនេះមានសកម្មភាពកាន់តែខ្លាំងឡើងៗដើម្បីធ្វើសេវាកម្មរបស់វា ។ ដើម្បីកាន់តែប្រសើររួមទាំងអន្តរស្ថាប័នអប់រំ និងការផ្សព្វផ្សាយទាំងពិភពលោកតាមរយៈអ៊ុនធើណែត ។

បណ្ណាល័យ



សូមអញ្ជើញអ្នកទទួលខុសត្រូវកាន់បណ្ណាល័យផ្សេងៗក្នុងមូលដ្ឋានរបស់អ្នកត្រូវពិភាក្សាគ្នា អំពីសកម្មភាពក្នុងម៉ូឌុលនេះដែលពួកគេមានតួនាទីជាធនធានខាងក្រៅ ។ រឿងនេះនឹងមានប្រយោជន៍ពិសេស ប្រសិនបើបណ្ណាល័យត្រូវបានបញ្ចូលក្នុងអ៊ុនធើណែត ហើយមានកុំព្យូទ័រសម្រាប់យុវជនរួមបញ្ចូលទាំងការបណ្តុះបណ្តាលតាមការចាំបាច់ ។ បណ្ណាល័យក្នុងប្រទេសជាច្រើនផ្តល់សេវាកម្មសាធារណៈខានមិនបាន : ហើយអ្នកទទួលខុសត្រូវនឹងរីករាយណាស់ដោយបានធ្វើជាដៃគូក្នុងការអនុវត្តន៍គម្រោងរបស់អ្នក ។



សូមលោកទាក់ទងអ្នកទទួលខុសត្រូវបណ្ណាល័យទាំងអស់ក្នុងតំបន់របស់លោកអ្នក។ ទោះបីអ្នកនោះនៅក្នុងសាលារៀនអនុវិទ្យាល័យក៏ដោយ ហើយសូមអ្នកពន្យល់ដល់ពួកគេអំពីប្រភេទនៃគម្រោង ។ សូមសួរបញ្ជាក់ថាតើអ្នកទទួលខុសត្រូវបណ្ណាល័យព្រមអនុញ្ញាតិឱ្យក្រុមយុវជនចូលមកធ្វើការស្រាវជ្រាវឬទេ។ សូមបញ្ជាក់អំពីលទ្ធភាពដែលពួកគេអាចបង្ហាត់បង្រៀនដល់យុវជនអំពីរបៀបប្រើប្រាស់បណ្ណាល័យតាមលេខយោងរកឱ្យឃើញអ្វីដែលគេស្វែងរក-រកព័តិមាននិងកត់ត្រាព័តិមាន ។

សូមអ្នកសួរដល់អ្នកទទួលខុសត្រូវថាតើពួកគាត់អាចបណ្តុះបណ្តាលក្រុមយុវជនអំពីការប្រើប្រាស់អ៊ិនធើណែត បង្កើតអស័យដ្ឋានអ៊ីម៉ែលដោយឥតបង់ថ្លៃ ។ល។ យុវជនខ្លះមិនត្រូវការព័តិមានទេនៅពេលយុវជនផ្សេងទៀតត្រូវការព័តិមាននេះ ។ ព័តិមានស្តីពីពលកម្មកុមារមានផ្សាយតាមអ៊ីនធើណែតច្រើនណាស់ ។ អ៊ិនធើណែតមានប្រយោជន៏ខ្លាំងណាស់ប្រសិនបើក្រុមយុវជនចេះប្រើវា ។

បណ្ណាល័យអាចបង្កើត "បញ្ជីអាន" សៀវភៅប្រលោមលោក សៀវភៅអប់រំដែលមានខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទពលកម្មកុមារ អាជីវកម្មកុមារនិងធ្វើការផ្សព្វផ្សាយដល់ក្រុមយុវជន។ មានអ្នកនិពន្ធជាច្រើនជុំវិញពិភពលោកដែលបានលើកកម្ពស់យុត្តិធម៌សង្គមក្នុងសៀវភៅរបស់គេ ។ បណ្ណាល័យនឹងក្លាយជាវេទិកាល្អមួយដែលណែនាំបង្ហាញដល់ក្រុមយុវជននូវសៀវភៅទាំងនេះនិងលើកទឹកចិត្តពួកគេឱ្យបានច្រើនទៀតអំពីប្រធានបទកុមារពលកម្មនេះ ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ម៉ូឌុលទាំងឡាយផ្តោតទៅលើរាល់ទម្រង់នៃសិល្បៈក៏ដូចជាឧបករណ៏សម្រាប់សម្តែង និងធ្វើសកម្មភាពនិងពាក្យពេចន៏សរសេរក្នុងសៀវភៅនេះមានថាមពលខ្លាំងក្លាណាស់ចំណុចនេះ ។ សូមឆ្លៀតឱកាសអានសៀវភៅបណ្តុះគំនិតដើម្បធ្វើផែនការការបញ្ចូលគ្នានូវម៉ូឌុលទាំងពីរនេះ ។ អ្នកនិពន្ធក្នុងស្រុកឬថ្នាក់ជាតិដែលត្រូវគេស្គាល់តាមរយៈការងារក្នុងបណ្ណាល័យអាចជាធនធានមនុស្សដែលអ្នកអាចអញ្ជើញឱ្យមកជួយរៀបចំសរសេរសៀវភៅបណ្តុះគំនិត។ សូមកត់ឈ្មោះរបស់

គេសហប្រតិបត្តិការ និងទំនាក់ទំនង ដើម្បីនិយាយអំពីគម្រោងរបស់អ្នកប្រាប់ដល់ពួកគេ ។ សូមអញ្ជើញអ្នកនិពន្ធឱ្យនិយាយទៅកាន់ក្រុមយុវជនអំពីស្បៀវភៅដែលគេបានសរសេរ និងអំពីថាមពលនៃពាក្យពេចន៍សរសេរ ដើម្បីរំលេចឡើងនូវបញ្ហាសិទ្ធិមនុស្ស និងតម្រូវការធ្វើសកម្មភាព ។

សមាហរណកម្ម សហគមន៍

អ្នកអាចស្នើឱ្យយោបល់សូមឱ្យបណ្ណាល័យក្នុងស្រុករបស់អ្នកបង្កើតឡើងនូវ "ជ្រុងនៃពលកម្មកុមារ" ដើម្បីឱ្យមានសកម្មភាពដំណាលគ្នា នឹងរយៈពេលដែលអ្នកអនុវត្តគម្រោងនេះជាមួយក្រុមយុវជន ។ ប្រសិនបើអ្នកធ្វើការក្នុងក្របខ័ណ្ឌសាលារៀនណាមួយ អ្នកអាចមានផលប៉ះពាល់ និងឥទ្ធិពលយ៉ាងសម្បើមទៅលើសិស្សផ្សេងៗទៀត។ ដោយហេតុថាការចង់ចេះចង់ដឹងរបស់គេនឹងភ្ញាក់រឭកឡើង ដោយសារការលេចចេញមកនូវពលកម្មកុមារក្នុងបណ្ណាល័យសាលារៀន ។ ទោះបីជាយ៉ាងណាក៏ដោយវានឹងអាចធ្វើឱ្យទិដ្ឋភាពអប់រំសហគមន៍ប្រសើរឡើងផងដែរកាលណាអ្នកប្រើប្រាស់បណ្ណាល័យផ្សេងទៀតកត់សម្គាល់ផ្នែកពលកម្មកុមារនេះ ហើយនាំគ្នាមកធ្វើការស្រាវជ្រាវដោយខ្លួនឯង ។ អង្គការលុបបំបាត់ពលកម្មកុមារអន្តរជាតិ (IPEC) មានផ្ទាំងរូបប្លែកៗ និងរូបភាពសម្រាប់បញ្ចាំងតាមសំណូមពរ ។ សូមធ្វើការជាមួយក្រុមយុវជន និងបណ្ណាល័យដើម្បីបង្កើតកន្លែងដាក់តាំងស្បៀវភៅ និងប្រលោមលោកទាក់ទងទៅនឹងពលកម្មកុមារ សិទ្ធិកុមារ ស្បៀវភៅស្តើងៗ ប័ណ្ណផ្គត់ស្តិតិ និងការងារខ្លះរបស់ក្រុមដូចជាគំនូររឿងខ្លីៗ ។ល។ វានឹងផ្តល់ឱ្យក្រុមនូវស្មារតីពោរពេញដោយមោទនភាពនិងអនុភាព ។ ក្រៅពីការងារផ្ទាល់របស់សហគមន៍ ត្រូវតែទទួលយកទៅដោះស្រាយនូវបញ្ហាពលកម្មកុមារ ។

សហជីព និងអង្គការក្រៅរដ្ឋាភិបាល

ប្រភពដែលមានសក្តានុពលស្តីពីបញ្ហាសិទ្ធិមនុស្សក្នុងប្រទេសភាគច្រើន គឺចលនាសហជីព អង្គការរបស់ពលករ និងអង្គការក្រៅរដ្ឋាភិបាល ។ សហជីពតំណាងឱ្យមនុស្សដែលកំពុងធ្វើការងារ និងការពារផលប្រយោជន៍សិទ្ធិរបស់ពលករ និងគ្រួសារ

របស់គេ។ គេអាចផ្តល់ព័តិមានអំពីសិទ្ធិរបស់កម្មករ សិទ្ធិរបស់ពលកររ៉ែយក្មេង សិទ្ធិរបស់ពលករដែលអាចធ្វើការមិនពេញម៉ោង, សេវាកម្មសហជីព។ល។ ម្យ៉ាងទៀតអង្គការក្រៅរដ្ឋាភិបាលជាផ្នែកមួយនៃបណ្តាញអន្តរជាតិរបស់អង្គការមនុស្សធម៌ដែលមានការយកចិត្តទុកដាក់ទៅនឹងការរំលោភសិទ្ធិមនុស្ស ។ សហជីព និងអង្គការក្រៅរដ្ឋាភិបាលអាចផ្តល់ព័តិមានផ្សេងទៀត អំពីបញ្ហាដូចជាពលកម្មកុមារ និងការរំលោភសិទ្ធិកុមារ។

ម្យ៉ាងទៀត អង្គការមួយចំនួនមានគម្រោងជួយកុមារពលកម្ម និងគ្រួសាររបស់គេក្នុងប្រទេសរបស់អ្នកនិងប្រទេសផ្សេងៗជុំវិញពិភពលោក ។សូមអញ្ជើញតំណាងអង្គការម្នាក់ឱ្យមកនិយាយទៅកាន់យុវជនអំពីបញ្ហាទាំងនេះ។ ម្យ៉ាងវិញទៀត សូមលើកទឹកចិត្តក្រុមយុវជនឱ្យទាក់ទងអង្គការទាំងនេះដើម្បីស្នើសុំព័តិមានសំខាន់ៗ និងជាក់ស្តែង ។

អ្វីដែលអ្នកត្រូវការ





សម្ភារៈសម្រាប់ធ្វើការងារជាមួយក្រុមអ្នក អាស្រ័យទៅលើទីកន្លែង និងធនធាន ដែលអាចរកបាន ។ យើងយល់ថាមធ្យោបាយសម្រាប់អនុវត្តម៉ូឌុលនេះអាចប្រែប្រួលពីបរិបទមួយទៅបរិបទមួយទៀត ។

ឧបសម័ន្ធទី ១ ផ្តល់នូវសេចក្តីលម្អិតនៃការបោះពុម្ពផ្សាយ និងវែបសៃ ដែលមានប្រយោជន៍សម្រាប់យុវជនក្នុងការស្រាវជ្រាវរបស់គេ ។ ធនធានមួយចំនួនបានមកដោយសារការទាក់ទងផ្តាល់នឹងការិយាល័យនៃកម្មវិធីលុបបំបាត់ពលកម្មកុមារ (IPEC) នៅក្រុងហ្សឺណែវ ។ ម្យ៉ាងទៀតអ្នកត្រូវការៈ

-ក្រដាស់ ឬស្លាបប៉ាកាឬខ្មៅដៃ

-ការប្រើប្រាស់អ៊ិនធើណែតប្រសិនបើអាចរកបាន

-ព័តិមានលម្អិតពីក្រសួងការងារ(ស្ថាប័នប្រហាក់ប្រហែលក្នុងប្រទេសរបស់អ្នក) និងផ្នែកពលកម្មក្នុងស្រុក ដើម្បីធ្វើការស្រាវជ្រាវអំពីបទបញ្ជាផ្ទៃក្នុងពាក់ព័ន្ធការអប់រំ និងការប្រើប្រាស់យុវជន ។

-ក្តារខៀនខ្មៅ/ស ឬរបស់ផ្សេងទៀត

ការចាប់ផ្តើម

ការរៀបចំក្រុម



ការរៀបចំក្រុម អាស្រ័យទៅលើចំនួនយុវជន សមត្ថភាព និងការសន្យារបស់ពួកគេ ។ ម៉ូឌុលនេះទាក់ទងនឹងការទទួលនូវចំណេះដឹង ហើយជាការជាក់ស្តែងថ្នាក់រៀនឬកន្លែងប្រហាក់ប្រហែល គឺជាកន្លែងយ៉ាងល្អសម្រាប់អនុវត្តសៀវភៅនេះ ។ ក៏ប៉ុន្តែបន្ទាប់ពីនេះគេស្នើរដល់សមាជិករបស់ក្រុមឱ្យធ្វើការស្រាវជ្រាវរបស់គេ ។ នេះគឺជាការងារអាចធ្វើដោយបុគ្គល ឬដោយក្រុមតូចពីពីរទៅបួននាក់ ។ ប៉ុន្តែអ្នកត្រូវប្រុងប្រយ័ត្នបំផុតក្នុងការបង្កើតក្រុមទាំងនេះ ដើម្បីធានាតុល្យភាពដ៏ល្អមួយ ។

ប្រសិនបើលោកអ្នកអាចប្រើប្រាស់អ៊ិនធើណែតតាមរយៈបណ្ណាល័យ ឬស្ថាប័នប្រហាក់ប្រហែល អ្នកអាចដឹងចំនួនកុំព្យូទ័រដែលនៅទំនេរ ហើយអាចចែកពួកអ្នកជាក្រុមតូចៗទៅតាមករណីនេះ ។ យុវជនខ្លះអាចធ្វើការបានកាន់តែល្អក្នុងក្រុមតូចៗ នៅពេលពួកគេធ្វើការស្រាវជ្រាវនិងសរសេរលទ្ធផលនៃការស្រាវជ្រាវពួកគេអាចពិភាក្សាជជែកគ្នាអំពីបញ្ហាផ្សេងៗក្នុងចំណោមពួកគេ ។ ការស្រាវជ្រាវនឹងមិនសូវមានការចាប់អារម្មណ៍ប្រសិនបើគេធ្វើការរួមគ្នានោះ ។

សកម្មភាព ១ :

ពិភពលោកដែលភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក

បង្រៀន ១ ពេល



ការពង្រីកមជ្ឈដ្ឋាន

ជាបឋមយុវជនត្រូវយល់ឱ្យបានច្បាស់លាស់នូវមូលហេតុដែលបណ្តាលឱ្យពួកគេចាប់អារម្មណ៍នៅលើពលកម្មកុមារ ។ មានមធ្យោបាយងាយបំផុតពីរយ៉ាងសម្រាប់បង្ហាញការភ្ជាប់ទាក់ទងគ្នានេះ ។ សម្រាប់លំហាត់ទាំងនេះ, យុវជនគួរតែស្ថិតនៅក្នុងថ្នាក់រៀនមួយ ។

ចូរអ្នកស្នើរដល់បុគ្គលម្នាក់ៗឱ្យសរសេរឈ្មោះរបស់គេផ្ទាល់បង្កើនរង្វង់មូលឱ្យបានច្រើនក្នុងពាក់កណ្តាលសន្លឹកក្រដាស់ស្អាត ។ ជាការសរសេរតូចៗ ដោយផ្ទិតផ្លង់ដោយហេតុថាពួកគេត្រូវការកន្លែងធំសម្រាប់សរសេរ ។ ជុំវិញឈ្មោះរបស់គេ, គឺត្រូវសរសេរឈ្មោះមនុស្សពេញវ័យដែលគេស្គាល់ចំនួន ១០ នាក់ : ឪពុកម្តាយ, សមាជិកគ្រួសារ, ញាតិសណ្តាន, មិត្តភក្តិរបស់គ្រួសារអ្នកជិតខាង, គ្រូបង្រៀន, ម្ចាស់ហាង, សមាជិកក្លឹបកីឡា ។ល។

ឈ្មោះរបស់គេពេលនេះត្រូវព័ទ្ធជុំវិញដោយឈ្មោះមនុស្សពេញវ័យដប់នាក់ ។ បន្ទាប់មកសូមប្រាប់ដល់គេឱ្យរង្វង់មួយទៀត ពេលនេះសូមសរសេរឈ្មោះមនុស្សពេញវ័យទាំងនេះដែលអាចស្គាល់ ។ ជាធម្មតា យុវជនមិនអាចស្គាល់ឈ្មោះពិតប្រាកដជានិច្ចកាលនោះទេ ។ ជួនកាលពួកគេប្រហែលជានឹកស្មានឈ្មោះ ហើយពេលនោះគេអាចសរសេរ "និយោជក" ឬ "សហសេវិកនៃការងារ" តែម្តងទៅបន្ទាប់មកពួកគេសាកល្បងសរសេរឈ្មោះឱ្យបានដប់ សម្រាប់ឈ្មោះនីមួយៗនៃមនុស្សដប់នាក់ដំបូងគេ ។ ជាសរុបឈ្មោះ ១១១ ត្រូវបានសរសេរនៅលើសន្លឹកក្រដាស់ ។

សកម្មភាពបន្ទាប់តម្រូវឱ្យគេគូសបន្ទាត់ភ្ជាប់ឈ្មោះទាំងឡាយតាមការយល់ឃើញរបស់គេ ។ សហសេវិក នឹងស្គាល់គ្នាទៅវិញទៅមក ។ អ្នកខ្លះអាចជាសមាជិកក្លឹបកីឡាដូចគ្នា ឬក្រុមសាសនា គ្រូបង្រៀននឹងស្គាល់ឪពុកម្តាយ ។ល។ សន្លឹកក្រដាស់របស់គេ ពេលនោះមានសភាពដូចជាសំណាញ់ពីងពាងអញ្ចឹង ។

បន្ទាប់មកសូមអ្នកសួរគេថា តើពួកគេគិតសរសេរឈ្មោះបន្ថែមទៀត ជុំវិញរង្វង់មូលខាងក្រៅឬយ៉ាងណាហើយលើកទឹកចិត្តគេធ្វើ ប្រសិនបើគេអាចធ្វើបាន ។ នៅពេលនេះក៏អញ្ជើងដៃរសូមឱ្យគេគូសបន្ទាត់ភ្ជាប់ឈ្មោះផ្សេងៗ ។ នៅពេលចុងបំផុតឈ្មោះទាំងឡាយនៅលើសន្លឹកក្រដាស់ត្រូវតែគេគូសភ្ជាប់ដោយផ្ទាល់ឬដោយប្រយោលទៅ នឹងឈ្មោះ ដែលសរសេរកណ្តាលគេលើទំព័រក្រដាស ។

ចូរអ្នកផ្តល់សញ្ញាតាមលំដាប់លំដោយដែលពួលគេពិចារណាអំពីឈ្មោះ និងគូសបន្ទាត់ភ្ជាប់ឈ្មោះទាំងនេះ ។ ប្រសិនបើលើមធ្យមភាគម្នាក់ៗនៃអ្នកទាំងនោះស្គាល់ឈ្មោះមនុស្សពេញវ័យ ១00 នាក់ ហើយមនុស្សពេញវ័យម្នាក់ៗនៃមនុស្សពេញវ័យទាំងនោះស្គាល់មនុស្សប្រហែល ៥00 នាក់ផ្សេងទៀតសូមអ្នកណែនាំឱ្យពួកគេធ្វើការគិតលេខងាយៗមួយចំនួន ដើម្បីរកឱ្យឃើញថាយុវជនឬបុគ្គលម្នាក់ៗត្រូវបានភ្ជាប់ដោយប្រយោលទៅមនុស្សចំនួនប៉ុន្មាននាក់ ការភ្ជាប់ឈ្មោះគ្នានេះមានការកើនប្រែបបានទៅការអភិវឌ្ឍន៍នៃព័ត៌មានបច្ចេកវិទ្យានិងគមនាគមន៍ ។ សូមពន្យល់ទៅកាន់ក្រុមឱ្យដឹងថាដោយសារកម្រិតការងារនេះនៃការភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមកដែលយើងទាំងអស់ គ្នារ៉ាប់រងទទួលខុសត្រូវអំពីអ្វីកើតឡើងក្នុងពិភពលោក ។

ការភ្ជាប់ទំនាក់ទំនងដោយប្រយោល

ការភ្ជាប់ទំនាក់ទំនងគ្នាដែលមានប្រយោជន៍មួយទៀតដែលត្រូវធ្វើ ទំនាក់ទំនងផ្នែកខាង ដោយប្រយោល ការបរិភោគ និងការប្រើប្រាស់ផ្សារភ្ជាប់ទៅនឹង បុគ្គលដែលយើងមើលមិនឃើញ ។ លំហាត់នេះត្រូវតែអនុវត្តភ្លាមបន្ទាប់ពីលំហាត់ទីមួយ, ប៉ុន្តែលើកនេះលំហាត់មិនចាំបាច់សរសេរ ។ អ្នកគ្រាន់តែពិភាក្សាប្តូរយោបល់គ្នាទៅវិញទៅមក ដោយផ្ទាល់មាត់រវាងអ្នកអប់រំ និងក្រុមអ្នក ។

សូមសួរទៅក្រុមយុវជនប្រភេទសំណួរដូចតទៅ ។ អ្នកអាចបន្ថែមសំណួរផ្សេងទៀតដែលអាចធ្វើឱ្យក្រុម របស់អ្នកមានការចាប់អារម្មណ៍ហើយរំភើប ។

- តើគេបានទិញសម្លៀកបំពាក់ស្បែកជើងដែលផលិតក្នុងទ្វីបអាស៊ីអាមេរិកកណ្តាលឬអាមេរិក ឬទេ ? គេក៏ ឆែកផ្លាកសញ្ញានៃសម្លៀកបំពាក់របស់គេភ្លាមតែម្តង ។
- តើគេបានលេងកីឡាប្រភេទណា ដែលត្រូវការគ្រឿងបរិក្ខាផលិតនៅបរទេស ឬទេ? បាល់ទាត់, បាល់ឱប, កីឡាបាល់ទាត់ បាល់ទះ ធេន្នីស, បាល់មិនតុន ល្បែង

កូនគោលអង់គ្លេស ។ល។ គេបានពិនិត្យមើលថាតើទំនិញ ទាំងនោះបានផលិតនៅឯណា ឬទេ ? អ្នកផលិតបាល់ទាត់ដ៏ធំក្នុងពិភពលោកគឺឥណ្ឌា និងប៉ាគីស្ថាន ។

- តើគេបានទិញដោយតម្លៃថោកនូវឧបករណ៍អគ្គីសនីមកពីប្រទេសចិន ឬប្រទេសផ្សេងទៀតនៃទ្វីបអាស៊ីឬទេ?
- តើអ្នកបានបរិភោគអាហារសមុទ្រដែលបានចាប់នៅអាស៊ីអាគ្នេយ៍ ឬទេ ?
- តើគេបានបរិភោគស្ករសូកូឡា ឬបានផឹកតែ ឬកាហ្វេផលិតដោយក្រុមហ៊ុនចំនុះបរទេស ឬទេ ?
- តើគេបានទិញបាច់ផ្កាសម្រាប់មិត្តភក្តិ ឬសមាជិកគ្រួសារឬទេ ?
- តើគេបានធ្វើដំណើរទៅបរទេស និងស្នាក់នៅក្នុងសណ្ឋាគារ ឬមជ្ឈមណ្ឌលទេសចរសម្រាប់វិស្សមកាលឬទេ ?

សូមកត់ត្រារាល់ចម្លើយនៅលើក្តារខៀន ឬក្រដាស់ផ្ទាំងធំ សូមលើកទឹកចិត្តពួកគេឱ្យពិចារណាអំពីឧបករណ៍ផ្សេងៗ និងឆ្លើយប្រាប់ឱ្យបានពីស្តារកីឡា ដែលគេចូលចិត្ត ឬការឈប់សម្រាករបស់គេ។ ក្រុមនឹងរកឃើញនូវលំហាត់ដែលនាំឱ្យសប្បាយរីករាយ ។ បន្ទាប់មក, ឱកាសមួយដ៏ល្អសមស្រប សូមអ្នកនិយាយប្រាប់ដល់ពួកគេថាពួកគេឥឡូវបានទាក់ទងដោយប្រយោលទៅនឹងកុមារពលកម្មហើយ ។ មិនត្រឹមតែពួកគេយុវជននោះទេ, ប៉ុន្តែចំនួនប្រជាជនជាយុវជនបានភ្ជាប់ការទាក់ទងទៅលំហាត់ទីមួយក៏ត្រូវចាត់ទុកថាជាការភ្ជាប់ការទាក់ទងទៅនឹងពលកម្មកុមារដែរ ។ សូមពន្យល់ដល់ពួកគេពីហេតុផលនៃរឿងនោះ :

- កុមារត្រូវបានគេប្រើប្រាស់ក្នុងការផលិតទំនិញសម្រាប់នាំចេញ, ជាពិសេសវាយនភ័ណ្ឌ និង ទំនិញសម្រាប់កីឡា
- កុមារត្រូវបានគេប្រើប្រាស់ក្នុងផ្នែកឧស្សាហកម្មក្នុងទ្វីបអាហ្វ្រិកនិងអាមេរិកកណ្តាល ។
- កុមារអាចរកឃើញក្នុងការងារកសិកម្ម និងការដាំដំណាំនៅទ្វីបអាហ្វ្រិក-អាមេរិកកណ្តាល ដែលទីនោះមានកូកាវ (សម្រាប់ធ្វើស្ករសូកូឡា) តែ និង កាហ្វេ ។

- កុមារត្រូវបានគេប្រើប្រាស់ក្នុងរោងចក្រធ្វើម្ហូបអាហារជុំវិញពិភពលោកជាការងារផលិតកម្ម និងការរៀបចំ វែចខ្ចប់ជាដើម ។
- កុមារអាចត្រូវបានគេប្រើក្នុងឧស្សាហកម្មទេសចរ, ជាពិសេសមុខរបរដែលគេមើលមិនឃើញ, ដូចជាការសំអាត និងបោកអ៊ុតជាដើម ។
- កុមារអាចត្រូវបានគេប្រើប្រាស់ក្នុងឧស្សាហកម្មផ្សេងៗជុំវិញពិភពលោក(មិនត្រឹមតែក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះទេ) គឺដើម្បីផលិតគ្រឿងអគ្គីសនី , ឧបករណ៍វះកាត់, ម៉ូដបន្ទាប់បន្សំ, ផលិតផលកែវ និងព័រសឺឡែន ។ល។

សមាជិកនីមួយៗក្នុងក្រុមរបស់អ្នកកំពុងតែស្វែងរកការភ្ជាប់ក្លេងៗដោយប្រយោលទៅនឹងថ្នាក់ណាមួយ ។ សូមទាញអារម្មណ៍នៃសមាជិកក្រុមឱ្យផ្តោតអារម្មណ៍ទៅលើចំណុចនេះ និងពិចារណាដាក់បញ្ចូលគម្រោងនេះទៅ ក្នុងបរិបទកុមារពលកម្ម ។ ទិសដៅរបស់អ្នកតាមរយៈលំហាត់ទាំងពីរនេះគឺត្រូវពង្រីកស្មារតីទទួលខុសត្រូវចំពោះមុខកុមារពលកម្ម ។

ការធ្វើចំនួនពិត

នេះជាលំហាត់ងាយមួយនៃការនីកស្រមៃដែលបានរៀបចំសម្រាប់ជួយក្រុមក្នុងការប្រមើលមើលចំនួនកុមារ ដែលជាប់ទាក់ទងក្នុងពលកម្មកុមារជុំវិញពិភពលោក ។ រឿងនេះត្រូវតែរៀបចំឱ្យបានល្អដោយសន្តិភាព និងដោយអារម្មណ៍នឹងនរ ។ សូមប្រាប់ទៅយុវជនឱ្យធ្វើលួសង្គមនិងស្រួលត្រង់ណាក៏បានដូចជានៅក្នុងបន្ទប់ ។ នឹងលើអ្វីក៏បានគេធ្វើដូចជា គ្មានបញ្ហាអ្វីសម្រាប់លំហាត់នេះទេ ។ បរិយាកាសត្រូវផ្តល់អំណោយផលល្អដល់ការនីកស្រមៃរបស់យុវជនដោយគ្មានការរំខាន ។ យុវជនមួយចំនួនអាចសម្គាល់ឃើញថាលំហាត់នេះមានការលំបាកបន្តិច,ជាពិសេសចំពោះវ័យជំទង់ប៉ុន្តែសូមឱ្យគេទាំងអស់គ្នាខំទ្រាំតស៊ូជាមួយអ្នក និងកុំធ្វើវាឱ្យមានការខូចខាត ។ ប្រសិនបើមានបុគ្គលខ្លះដែលអាចនឹងធ្វើឱ្យគាត់បាត់លំនឹងខូចបរិយាកាស ដែលអ្នកបានបង្កើតឡើង ប្រសិនបើគេបដិសេធន៍រាល់ការប្រឹងប្រែង របស់អ្នកក្នុងការនាំគេទាំងអស់គ្នាឱ្យធ្វើលំហាត់, នោះសុំឱ្យគេអាន ឬធ្វើអ្វីផ្សេងទៀតដោយស្ងៀមស្ងាត់បំផុត ។ លំហាត់គឺត្រូវតែខ្លីបំផុត ។

ល្អបំផុតរឿងដែលយុវជនត្រូវបិទភ្នែករបស់គេក្នុងរយៈពេលធ្វើលំហាត់នេះ ។ សូមនិយាយទៅកាន់ពួកគេ ឱ្យនឹកថាពួកគេក្នុងពេលនេះកំពុងធ្វើដំណើរឆ្លាយតាមផ្លូវចង្អៀត ។ នៅផ្នែកខាងស្តាំដៃមានក្អែងស្ថិតនៅ ជាជួរដោយខ្លួនប្រាណ កខ្វក់, មិនស្អាតបាត, ខ្លងកោង, ជើងទទេ, តូច, ខ្វះជីវជាតិអាហារ និងសម្លឹងមើលក្រុមយុវជនដើរទៅមិនដាក់ភ្នែកដោយក្តីព្រួយកង្វល់, និងអង្វរកុមារទាំងនេះស្ថិតនៅឃ្លាតពីគ្នាមួយម៉ែត្រ ឬម្ភាក់ៗពីរដំហានពីគ្នា។

សូមប្រាប់ទៅក្រុមយុវជនឱ្យពិនិត្យមើលមុខកុមារទាំងអស់នេះ នៅពេលដែលគេដើរទៅជិត ។ ពួកគេមិនត្រូវគេច មិនព្រមពិនិត្យមើល ក្នុងរង្វង់ភ្នែកគេឡើយ។ យុវជនត្រូវសម្លឹងមើលក្រសែភ្នែកដ៏ក្រៀមក្រមរបស់កុមារ ហើយបង្ហាញទៅវិញនូវក្រសែភ្នែកពោរពេញដោយថាមពល និងក្តីសង្ឃឹមដល់ពួកក្មេងៗទាំងនោះ ។

បន្ទាប់មកសូមប្រាប់ទៅក្រុមយុវជនថាពួកគេបានធ្វើដំណើររបស់គេប្រហែលនៅវេលាម៉ោង ៨ព្រឹក-គេមានពេលទទួលទានអាហារពេលព្រឹក និងមានអារម្មណ៍ឆ្អែតបាត់ឃ្លាន ។ ការឆ្អែតធ្វើឱ្យគេមានអារម្មណ៍រសាប់រសល់ យ៉ាងខ្លាំងពេលគេសម្លឹងមើលមុខមាត់ស្រេកឃ្លានរបស់កុមារពលកម្មគេចាប់ផ្តើមមានអារម្មណ៍ ថាពួកគេមានការខុសឆ្គង ។ គេបន្តដើរទៅមុខពេញមួយព្រឹក, ដើរហួសកុមារម្ភាក់រាល់ពីរដំហាន ។ គេបន្តដើរតាមបណ្តោយផ្លូវវែងត្រង់ និងចង្អៀត ។ សូមលើកទឹកចិត្តគេឱ្យដើរទៅជិតកុមារនិងមើលឱ្យឃើញថា តើពួកគេអាចស្តាប់កុមារទាំងនោះបានដែរឬទេ ។

ពួកគេនាំគ្នាដើរ, ដើរ, ដើរពេញមួយទិវា ។ ក្រោយបានដើរមួយកំណាត់ព្រឹក ,ពួកគេឈប់ និងងាកមើលតាម បណ្តោយផ្លូវដ៏វែងដែលពួកគេបានដើរមក ។ គេមើលឃើញជួរកុមារលាតសន្ធឹងយ៉ាងវែងនៅពីក្រោយពួកគេ ។ ពួកកុមារទាំងអស់គ្នាសម្លឹងមើលសមាជិកក្រុមដែលដើរទៅមុខ ។ ភ្នែករាប់លានដែលមានភាពទុក្ខព្រួយ និងអង្វរករ ដោយមានន័យថាសូមមេត្តាជួយសង្គ្រោះពួកគេផង ដោយស្ងៀមស្ងាត់ក្រុមយុវជនងាកមើលម្តងទៀត ហើយឃើញជួរកុមារីលាតសន្ធឹងទៅឆ្ងាយ, ឆ្ងាយដាច់កន្ទុយភ្នែកក្រុមយុវជនក៏ធ្វើដំណើរទៅតាមផ្លូវនោះជាបន្តទៅទៀត ។

គេដើរហួតដល់ពេលអាហារថ្ងៃត្រង់, អាហារពេលល្ងាច និងដល់ពេលល្ងាចយប់ ។ ពេលនោះនៅតែមានជួរកុមារលាតសន្ធឹងយ៉ាងវែងពីមុខ និងពីក្រោយគេ ។ គេដើរហួតដល់ម៉ោង ១០ យប់ ។ គេឈប់ហើយគិតថាឥឡូវដើរអស់រយៈពេល ១៤ ម៉ោងស្មើរតែគ្មានឈប់។ គេអស់កម្លាំងហើយដែលដើរបញ្ច្រាសទិស បានជួបកុមារប្រហែល ៨0000នាក់ ។ សូមជូនដំណឹងទៅក្រុមថាគេគួរតែដើរដូចនេះអស់រយៈពេលជិតបួនថ្ងៃមុននឹងជួបកុមារទាំងអស់ ដែលត្រូវបង្ខំឱ្យទៅរួមចំណែកក្នុងជម្លោះប្រដាប់អាវុធជុំវិញពិភពលោក ។

ពួកយុវជនត្រូវតែឈប់ ពេលយប់ដើម្បីសម្រាក ដេក និងទទួលទានអាហារ ។ ដូច្នេះគេបោះជំរុំនៅក្បែរផ្លូវនៅខាងឆ្វេងដៃដើម្បីឱ្យគេដេក និងមើលទៅជួរកុមារដែលនៅម្ខាងផ្លូវ។ កុមារទាំងឡាយដោយស្ងៀមស្ងាត់នាំគ្នាសម្លឹងមើលសមាជិកក្រុមទាំងឡាយដែលដេកលក់ ។

យោងតាមស្ថិតិពីម៉ូឌុលមូលដ្ឋានព័តិមាន, សូមឱ្យសមាជិកក្រុមធ្វើហាក់ដូចជាមើលជួរដ៏វែងនៃកុមារធ្វើពលកម្មដែលមិនអាចគួរឱ្យជឿ បន្ទាប់មកសូមរំឭកគេឡើងវិញថា ពួកគេបានជួបកុមារពលកម្មប្រហែល ៨0000 នាក់ក្នុងមួយទិវាពេញនេះ ។ មានកុមារធ្វើពលកម្មក្នុងពិភពលោកមានចំនួនប្រហែល ១៨៦ នាក់ដែល ស្ថិតក្នុងចន្លោះអាយុពី ៥ ទៅ ១៤ ឆ្នាំ។ សូមស្នើទៅក្រុមឱ្យនឹកស្រមៃថាតើត្រូវការរយៈពេលប៉ុន្មានដើម្បីដើរឆ្លងកាត់កុមារទាំងនេះ ដែលកំពុងធ្វើការក្នុងតំបន់ដូចតទៅ :

- ទ្វីបអាស៊ី និងតំបន់ប៉ាស៊ីហ្វិក (ប្រមាណ ១២៧ លាននាក់) ?
- អាមេរិកឡាទីន និងការ៉ាអ៊ីត (ប្រមាណ ១៧៥ លាននាក់)?
- វាលសាហារ៉ាទ្វីបអាហ្វ្រិក (ប្រមាណ ៤៨ លាននាក់) ?
- ប្រទេសអភិវឌ្ឍន៍ (ប្រមាណ ២,៥ លាននាក់) ?

ប្រសិនបើអ្នកបានរកឃើញស្ថិតិផ្សេងៗដោយខ្លួនអ្នកផ្ទាល់, សូមប្រើប្រាស់ស្ថិតិនេះតាមដំណើរក្នុងដំណាក់កាលនេះ ។ ក្នុងរយៈពេលមួយសន្ទុះសូមឱ្យក្រុមយុវជនអង្គុយបិទភ្នែកហើយនឹកស្រមៃចំនួនកុមារដែលបានជាប់ពាក់ព័ន្ធនឹងកុមារពលកម្មដែល

ដើរជាជួរតាមផ្លូវក្នុងស្រមៃ ។ បន្ទាប់មកសូមរំឭកពួកគេគិតដល់ភាពពិត និងឱ្យគេបើកភ្នែកឡើងវិញ ។

សូមឱ្យពួកគេនិយាយដោយសង្ខេបអំពីបទពិសោធន៍របស់គេអំពីអ្វីដែលបានឃើញ ហើយមានអារម្មណ៍ ។ ពួកគេត្រូវតែនិយាយបញ្ចេញប្រតិកម្មរបស់គេ ។

កំណត់សម្គាល់សម្រាប់អ្នករៀបចំគ្រាស់

នៅពេលសាកល្បងលើកទឹកចិត្តយុវជនឱ្យនឹកស្រមៃរបស់គេ សូមចងចាំថានេះជាអ្វីមួយដែលគេមិនធ្លាប់បានធ្វើនិងប្រើប្រាស់ជាធម្មតាឡើយ ។ នៅក្នុងការអប់រំក្នុងប្រព័ន្ធក៏ដូចជាក្រៅប្រព័ន្ធដែរ ។ កុមារទាំងឡាយប្រើការស្រមៃរបស់គេជាញឹកញាប់កាលនៅពីក្មេងក្នុងការអប់រំបឋមសិក្សា ។ ជាអកុសល, ប្រព័ន្ធអប់រំនៅកម្រិតមធ្យមសិក្សា ក្នុងប្រទេសមួយចំនួនមាននិន្នាការទៅរកការមិនពង្រីកការនឹកស្រមៃឡើយ ។ នេះគឺជាស្មារតីដែលទាមទារឱ្យមាន ការអនុវត្ត ដើម្បីឱ្យមានការភ្ញាក់ហើយរឿងនេះនឹងទៅជាលំហាត់មួយដ៏មានប្រយោជន៍ ។ សូមអ្នកកុំព្រួយបារម្ភប្រសិនបើលំហាត់បែបនេះទាមទារយៈពេលខ្លះ សម្រាប់ធ្វើឱ្យមានប្រសិទ្ធភាពនៅក្នុងក្រុម ។ ការងារនេះពឹងផ្អែក ជាច្រើនទៅលើសមត្ថភាព និងឆន្ទៈដើរមើលក្នុងចំណោមសមាជិករបស់ក្រុម និងប្រើប្រាស់សម្លេង និងភាសាផ្ទាល់របស់អ្នក ដើម្បីជំរុញឱ្យធ្វើការស្រមៃនៅពេលដែលពួកគេ ចង់មើលឃើញនឹងភ្នែកនូវផ្លូវដ៏វែង និង ជួរកុមារពលកម្មនៅតាមដងផ្លូវនោះ ។

សូមអ្នកព្យាយាម ជោគជ័យនៃម៉ូឌុលនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើការស្រមៃនិងការបិទប្រសប់ច្នៃប្រឌិតរបស់យុវជន ។ ម៉ូឌុលទាំងនេះ ប្រើប្រាស់រាល់ទម្រង់នៃសិល្បៈ-នៃចក្ខុវិញ្ញាណ, អក្សរសាស្ត្រ និងការសម្តែងក្នុងបំណងបង្កើតឱ្យមានលទ្ធផលយូរអង្វែង ។ ដូច្នេះវាសំខាន់រឿងដែលធ្វើមានការស្រមៃច្រើនឡើងក្នុងដំណាក់ការដំបូងបំផុត ដែលអាចមានលទ្ធភាពធ្វើការបាន ។

សកម្មភាព ២:

ពលកម្មកុមារ និងសិទ្ធិមនុស្ស

បង្រៀន ១ ពេលជាប់គ្នា

ឥឡូវនេះក្រុមបានគិតថាមានក្រុមកុមារធ្វើពលកម្មបានបង្កើតទំនាក់ទំនងជាមួយ ហើយក៏កើតមានក្តីអស់សង្ឃឹម ។ ពេលនេះគឺជាពេលវេលាសមស្រប ដើម្បីផ្តួចផ្តើមការពិភាក្សាជាមួយគ្នាអំពីប្រភេទនៃពលកម្មកុមារ និង ក្រឡេកមើលបញ្ហានៅក្នុងបរិបទ នៃសិទ្ធិមនុស្ស ។ ពលកម្មកុមារគឺជាបញ្ហារបស់សិទ្ធិមនុស្សការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត និងជាក់ស្តែងបំផុតគឺសិទ្ធិកុមារ ។ ទោះជាយ៉ាងណាក៏ដោយ, កាលពីមុនរឿងនេះអាចបង្ហាញជាប្រធាន សម្រាប់ពិភាក្សាមួយចំពោះក្រុមជាការសំខាន់គឺត្រូវឱ្យតម្លៃទៅលើការយល់ដឹងអំពីសិទ្ធិមនុស្សរបស់គេជាមុន ទៅលើរបៀបដែលកុមារត្រូវបានរំលោភ និងរបៀបដែលសង្គមមានប្រតិកម្មចំពោះការរំលោភ។ នេះក៏ជាឱកាសដ៏ល្អមួយ ដើម្បីបង្ហាញនូវការទាក់ទងមួយចំនួនអំពីកិច្ចព្រមព្រៀងជាអន្តរជាតិ ដែលអនុវត្ត ជាពិសេសចំពោះសិទ្ធិមនុស្ស និងពលកម្មកុមារ ។

មានមធ្យោបាយពីរសម្រាប់បង្ហាញកិច្ចព្រមព្រៀងអន្តរជាតិ ។ មធ្យោបាយទីមួយ គឺស្វែងរកនិងថតចម្លងកិច្ចព្រមព្រៀងស្តីពីភារកិច្ចសម្រាប់ក្រុមយុវជន ។ មធ្យោបាយទីពីរ គឺត្រូវថតចម្លងផ្នែកសំខាន់នៃកិច្ចព្រមព្រៀងដែល បានបញ្ចូលក្នុងកញ្ចប់អប់រំ ។



សេចក្តីប្រកាសនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស

សូមអញ្ជើញសមាជិកម្នាក់នៃក្រុមឱ្យដើរតួជាអ្នករាយការណ៍ ។ មនុស្សនេះគួរសរសេរនៅលើក្តារខៀនចំណុចសំខាន់ៗ និងទស្សនៈដែលបានបញ្ចេញក្នុងរយៈពេលពិភាក្សា ។

គោលបំណងនៃសៀវភៅនេះ គឺបង្ហាញឱ្យឃើញច្បាស់នូវទំនាក់ទំនងរវាងពលកម្មរបស់កុមារ និងបញ្ហាសិទ្ធិមនុស្សក្នុងពិភពលោក ។ សូមសួរទៅកាន់យុវជននូវអ្វីដែលពួកគេស្តាប់ឮអំពីសិទ្ធិមនុស្ស ។ នៅពេលដែល យុវជនម្នាក់ៗឆ្លើយ និងពន្យល់

តើអ្វីជាអនុសញ្ញាអន្តរជាតិ ?

អនុសញ្ញាអន្តរជាតិនេះ គឺជាកិច្ចព្រមព្រៀង រវាងប្រទេសបង្កើតច្បាប់ដោយផ្អែកលើបទដ្ឋានអនុម័តយល់ព្រមដោយប្រទេសច្រើន។ កិច្ចព្រមព្រៀងទាំងនេះជាធម្មតាបានតាក់តែងក្នុងក្របខ័ណ្ឌរបស់អង្គការអន្តរជាតិផ្សេងៗ។រដ្ឋាភិបាលដែលចុះហត្ថលេខា និង ធ្វើសច្ចាប័ណ្ណកិច្ចព្រមព្រៀងទាំងនេះត្រូវបញ្ចូលកិច្ចព្រមព្រៀងនេះទៅក្នុងច្បាប់របស់គេផ្ទាល់ និង ធ្វើឱ្យគេគោរព និង អនុវត្ត និងគោរពកិច្ចព្រមព្រៀងនេះ នៅក្នុងប្រទេសណាមួយក្រីក្រពេក ឬក៏ធំពេកអ្នកអាចស្រមៃថាតើការដាក់ឱ្យនេះគោរព និងអនុវត្តច្បាប់នេះជួបការពិបាកយ៉ាងណាទៅ។ បញ្ហានេះត្រូវការមនុស្សត្រួតពិនិត្យ ការអនុវត្តន៍ និងការគោរពច្បាប់ ឧទាហរណ៍ អធិការនៃពលកម្ម ។ មនុស្សមានតម្លៃប្រាក់ រឿងនេះជាការពិបាកសម្រាប់ប្រទេសក្រីក្រ និងប្រទេសធំៗ ដែលទាមទារអ្នកធ្វើការងារយ៉ាងច្រើន ។ ដូច្នេះរដ្ឋាភិបាលខ្លះត្រូវការជំនួយ និងគាំទ្រក្នុងផ្នែកពលកម្មកុមារ, ជាពិសេស IPEC ។

អំពីអ្វីដែលហៅថាសិទ្ធិមនុស្សនោះ សូមជំរុញពួកគេឱ្យពណិនាលម្អិតដោយចោទសួរ អំពីរបៀបដែលសិទ្ធិមនុស្សត្រូវការ ។ ប្រសិនបើពួកគេស្គាល់របៀបបំពានណាមួយដែលគេបានអានក្នុងសារព័តិមាន ឬបានឃើញតាមរយៈទូរទស្សន៍ ។

តាមលំដាប់នៃសិទ្ធិមនុស្សដែលត្រូវបានរំលោភ និងកត់សម្គាល់នោះ, សូមសង្កេបឱ្យសិស្សកត់ត្រាលទ្ធផល នៃការពិភាក្សាគ្នា ដើម្បីឱ្យលទ្ធផលត្រូវបានសរសេរច្បាស់លាស់ ។ លើកទឹកចិត្ត និងជំរុញការពិភាក្សាប្តូរយោបល់គ្នាទៅវិញទៅមកឱ្យរស់រវើកតាមដែលអាចធ្វើទៅបាន ។ ប្រសិនបើក្រុមមិនអាចនឹកឃើញចំណុចជាគន្លឹះទាំងឡាយ, សូមដឹកនាំគេទៅកាន់ចំណុចនោះដោយផ្ទាល់ និងលើកទឹកចិត្តជំរុញការពិភាក្សាជុំវិញបញ្ហាទាំងនេះ ។ សូមដឹកនាំ ការពិភាក្សាឱ្យស្តីពីបញ្ហាសិទ្ធិមនុស្សជានិច្ច ។

លុះការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកចាប់ផ្តើមស្ងាត់ សូមអ្នកបង្ហាញប្រធានបទនៃការពិភាក្សាបន្ទាប់ទៀតដូចជាតើសិទ្ធិទាំងនេះ ត្រូវបានការពារ និងធ្វើឱ្យមនុស្សស្គាល់ជុំវិញពិភពលោកដោយរបៀបណា។ គោលបំណងរបស់អ្នកពេលនេះ គឺជំរុញអ្នកណាមួយឱ្យគូសបញ្ជាក់សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (សេចក្តីចម្លងមានក្នុងកញ្ចប់) ។

សូមផ្តោតអារម្មណ៍ទៅលើសេចក្តីប្រកាសនេះក្នុងរយៈពេលមួយ និងជំរុញឱ្យមានការពិភាក្សាជុំវិញសេចក្តីប្រកាសនេះ ។ ប្រសិនបើគេមិនពិភាក្សាទេ, សូមដឹកនាំការពិភាក្សានេះដោយអ្នកផ្ទាល់ ។

សូមស្នើដល់ពួកឱ្យពន្យល់តួនាទី និងមុខងាររបស់អង្គការសហប្រជាជាតិ ។ សូមសួរថាតើមានអ្នកណាម្នាក់ដឹងនូវវចនៈស័ព្ទដែលចែងថា : "ស្ថាប័នឯកទេសអង្គការសហប្រជាជាតិ" ឬទេ? ជាពិសេស, អង្គការពលកម្មកុមារអន្តរជាតិ(ILO)ជាដើម។ រឿងនេះ និងជួយក្រុមឱ្យយល់អំពីស្ថានភាពរបស់ ILOក្នុងការពិភាក្សានិងតួនាទីរបស់ ILOក្នុងការលុបបំបាត់ពលកម្មរបស់កុមារ។

ប្រសិនបើអ្នកមានអត្ថបទនៃសេចក្តីប្រកាសសិទ្ធិមនុស្សអ្នកត្រូវថតចម្លង (បើអាចធ្វើបាន)ឱ្យដល់សមាជិកក្រុម ។ ឬម្យ៉ាងទៀត, អ្នកអាចព្យួរឬបិទសេចក្តីប្រកាសនៅលើជញ្ជាំងសម្រាប់ក្រុមសិក្សា និងអាននៅពេលទំនេរ។ សូមចាប់ផ្តើមបង្ហាញសិទ្ធិជាមូលដ្ឋានគ្រឹះ ហើយសួរគេថាតើគេបានដឹងអំពីការរំលោភក្នុងប្រទេសរបស់គេ ឬជុំវិញពិភពលោកឬទេ ? សូមពិភាក្សាគ្នាអំពីការរំលោភទាំងនេះ និងនាំគេឱ្យពិចារណារកមូលហេតុដែលនាំឱ្យសេចក្តីប្រកាសអន្តរជាតិដែលមានអាយុ៥0 ឆ្នាំមកហើយត្រូវបានរំលោភ ។ សួរគេប្រសិនបើសិទ្ធិត្រូវបានរំលោភនៅកន្លែងផ្សេងៗទៀតក្នុងពិភពលោក, សូមសួរដល់ពួកគេថាតើប្រទេសដទៃទៀតគួរយកចិត្តទុកដាក់ជួយដោះស្រាយទាំងនោះឬយ៉ាងណា ?

តើគេមានយោបល់ដូចគ្នាឬទេអំពីពលកម្ម? សូមអ្នកកុំភ្លេចធ្វើឱ្យមានស្មារតីភ្ញាក់រលឹកយកចិត្តទុកដាក់ និងទទួលខុសត្រូវចំពោះកុមារពលកម្ម ។

អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ

នៅពេលជជែកគ្នាអំពីសិទ្ធិមនុស្សជាមួយក្រុម, សូមបង្ហាញទស្សនៈនៃសិទ្ធិកុមារ និងសួរក្រុមថាតើពួកគេមានអារម្មណ៍ចំពោះ កុមារ និងយុវជនគួរមានសិទ្ធិជាក់លាក់ ហើយនិងត្រូវបានគោរពដោយមនុស្សពេញវ័យ និងអាជ្ញាធរឬទេ? សូមចាត់តាំងអ្នកណាម្នាក់ឱ្យកត់ត្រាចំណុចសំខាន់ៗដែលបានលើកឡើង ។ សូមសួរដល់ក្រុមថាតើពួកគេ ដឹងឧបករណ៍ណាមួយ, ស្រដៀងគ្នានឹងសេចក្តីប្រកាសអំពីសិទ្ធិមនុស្សរបស់សហប្រជាជាតិ, ដែលការពារសិទ្ធិកុមារ និងដែលបានអនុម័តស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក។ គោលបំណងនៃការសួរគឺចង់មើលឱ្យឃើញ ថាតើអ្នកណាខ្លះក្នុងចំណោមនោះដឹងថាមានអនុសញ្ញារបស់សហប្រជាជាតិស្តីអំពីសិទ្ធិរបស់កុមារ(ច្បាប់ចម្លងមានក្នុងកញ្ចប់) ប្រសិនបើមានលទ្ធភាពអ្នកត្រូវមានច្បាប់ចម្លងអនុសញ្ញារបស់សហប្រជាជាតិនេះនៅជាប់នឹងអ្នក , ឬក៏ព្យួរច្បាប់ចម្លងនៅក្នុងបន្ទប់សម្រាប់ឱ្យពួកគេមើលនៅពេលទំនេរ។ សូមប្រៀបធៀបចំណុចដែលកើតលើកឡើង ដោយក្រុមនិងមាត្រាក្នុងអនុសញ្ញា។ ប្រសិនបើអ្នកខ្លះមិនបានស្តាប់អនុសញ្ញានេះទេ សូមជជែកគ្នាអំពីមាត្រាគន្លឹះ

មួយចំនួនជាមួយគេ ជាពិសេសមាត្រាណា ដែលទាក់ទងនឹងការអប់រំសម្រាប់ទាំងអស់គ្នា (មាត្រា ២៨) និងមួយណាដែលមានការហាមប្រាមការជួញដូរកុមារ (មាត្រា ៣២)។

អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ លេខ ១៣៨ អំពីអាយុអប្បបរមា

សូមរំឭកឡើងវិញនូវការពិភាក្សាគ្នាស្តីពីស្ថាប័នឯកទេសផ្សេងៗ របស់សហប្រជាជាតិ ហើយពន្យល់ដោយសង្ខេបអំពីតួនាទីរបស់ ILO ។ ILO គឺជាស្ថាប័នសម្រាប់ពិភពការងារដែលខំប្រឹងប្រែងលើកកម្ពស់យុត្តិធម៌សង្គមនៅក្នុងប្រទេសជាសមាជិក ។ តួនាទីសំខាន់របស់ ILO គឺឃ្លាំមើលការគោរពសិទ្ធិជាមូលដ្ឋាននៅក្នុងកន្លែងធ្វើការ ហើយរឿងនេះអាចធ្វើទៅបានដោយសារតែកម្លាំងត្រីភាគី គឺកម្លាំងរដ្ឋាភិបាល និយោជក និងពលករ ។ សូមមើលម៉ូឌុលដែលមានចំណងជើងថា ពិភពការងារប្រសិនបើអ្នកចង់ឱ្យច្បាស់នូវតួនាទី និងវិធីធ្វើការរបស់ ILO ។

សូមទាញអារម្មណ៍របស់សិស្សឱ្យផ្តោតទៅលើសញ្ញាជាក់លាក់លេខ ១៣៨ (ច្បាប់ចម្លងមានក្នុងកញ្ចប់) និងពន្យល់ថានេះជាអនុសញ្ញាដែលជាគ្រឹះនៃយុទ្ធនាការដើម្បីលុបបំបាត់ពលកម្មកុមារ ។ ចូរប្រើប្រាស់ច្បាប់ចម្លងនៃអនុសញ្ញារបស់អ្នក (និងចែកឱ្យគេច្បាប់ចម្លង បើសិនអ្នកអាចរកបាន) សូមសួរទៅក្រុមយុវជនថាតើគេដឹងពីបញ្ហាសំខាន់ សម្រាប់លើកឡើងមុនការផ្តើមពិនិត្យដោះស្រាយបញ្ហាពលកម្មកុមារ ឬទេ ? អ្វីដែលអ្នករកនៅទីនេះគឺ "និយមន័យ" នៃពលកម្មកុមារ ។ សូមសួរទៅគេថា តើគេសន្និដ្ឋានដូចម្តេចថាពលកម្មកុមារ អាចត្រូវបានគេឱ្យនិយមន័យ និងត្រូវបានគេឱ្យអត្តសញ្ញាណ (មានន័យថាអាយុស្របច្បាប់អាចឱ្យធ្វើការងារបានក្នុងប្រទេសណាមួយ)។ សូមស្តាប់ដោយប្រុងប្រយ័ត្នចំពោះការឆ្លើយតបរបស់គេ និងកត់ត្រាចម្លើយណាត្រឹមត្រូវ ឬជិតត្រឹមត្រូវជាងគេ ។ សូមលើកទឹកចិត្តពួកគេតាមរយៈ

សំណួរ និង ជំរុញឱ្យមានការជជែកពិភាក្សាគ្នា រហូតដល់ពេលអ្នកស្តាប់ឮនូវចម្លើយត្រឹមត្រូវ ។

អនុសញ្ញាស្តីអំពីអាយុអប្បបរមានាំឱ្យមានគោលនយោបាយច្បាស់លាស់សម្រាប់ឱ្យរដ្ឋាភិបាល កំណត់អាយុអប្បបរមាដែលអនុញ្ញាតិឱ្យកុមារធ្វើការងារក្នុងប្រទេសផ្សេងៗ ។ អនុសញ្ញាកំណត់ឱ្យកុមារទាំងឡាយត្រូវតែបំពេញកាតព្វកិច្ចអប់រំមុននឹងអនុញ្ញាតិឱ្យធ្វើការងារពេញម៉ោង ។ គេអនុញ្ញាតិផងដែរការងារ ស្រាលៗ, ដូចជាមើលថែផ្ទះ, ការងារប្រចាំថ្ងៃជាដើម ហើយមិនអនុញ្ញាតិឱ្យធ្វើ ការពេលយប់ និងការងារធ្ងន់ៗប្រហាក់ប្រហែលនឹងការងារជាដើម ។ ទោះបីអនុសញ្ញាពិភពលោកនេះត្រូវបានគេចាត់ទុកជា ឧបករណ៍អន្តរជាតិសំខាន់តែមួយគត់ ក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារក៏ដោយ ក៏អនុសញ្ញានោះប្រើភាសាដែលពិបាកខ្លាំង ដើម្បីឱ្យយុវជនយល់យ៉ាងងាយសូមប្រយ័ត្នកុំឱ្យក្រុមរបស់អ្នកធុញទ្រាន់ ដោយសារការបរិយាយលម្អិតខ្លាំងពេក ។



សូមចាំថា គោលបំណងគឺមិនមែនធ្វើឱ្យក្រុមក្លាយជាជំនាញក្នុងការលុបបំបាត់ពលកម្មកុមារឡើយ។ ប៉ុន្តែត្រូវជួយគេទាំងនោះឱ្យយល់ថាមានអង្គការធំៗមួយចំនួនដែលបានសាកល្បងជួយរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាពលកម្មកុមារ ។ ទិសដៅរបស់អ្នកគឺបង្ហាញដល់ពួកគេនូវអនុសញ្ញាអន្តរជាតិសំខាន់ៗទាំងឡាយ។ ដើម្បីឱ្យគេទាំងអស់គ្នាដឹងអំពីអត្ថិភាពរបស់គេ ហើយអាចទទួលបានព័ត៌មានអំពីសាវតាមួយចំនួនរបស់គេ ។ ប៉ុន្តែមិនមែននិយាយអំពីអត្ថបទអនុសញ្ញានោះយូរពេកទេ ពីព្រោះវាអាចធ្វើឱ្យក្រុមយុវជនធុញទ្រាន់ ។

សូមពន្យល់ដល់ពួកគេទាំងអស់ថារដ្ឋាភិបាលទាំងឡាយ នឹងបញ្ចូលអនុសញ្ញាទៅក្នុងច្បាប់សម្រាប់ជាតិរបស់គេ ស្របតាមប្រទេសផ្សេងៗ អង្គការសហប្រជាជាតិមិនដឹកនាំពិភពលោកទេ-ប៉ុន្តែផ្តល់ក្របខ័ណ្ឌសម្រាប់ពិគ្រោះយោបល់និងផ្តល់ជំនួយឧបត្ថម្ភតាមការចាំបាច់ ។ មើលឱ្យឃើញតើក្រុមណាបានលើកឡើងនូវចំណុចណាមួយដែលមានប្រយោជន៍ខ្លាំងបើមានសញ្ញាដូច្នេះ។ ហើយហេតុអ្វីបានជាពលកម្មកុមារ គឺជាបញ្ហាដ៏ធំសម្បើមនិងហេតុអ្វីបានជាសិទ្ធិមនុស្សត្រូវបានគេរំលោភក្នុងពិភពលោក? នេះ

ជាបញ្ហាដ៏សែនធំដែលអាចនាំឱ្យមានការពិភាក្សាតាមបែបទស្សនៈវិជ្ជា និងប្រកបដោយសក្តានុពលទៅលើការអភិវឌ្ឍនយោបាយ, សេដ្ឋកិច្ច និងសង្គម ។ ប្រសិនបើមានឱកាសសម្រាប់ការពិភាក្សាដូចនេះសូមជំរុញឱ្យមានការពិភាក្សានោះទៅចុះ ។ ស្តាប់ទស្សនៈរបស់យុវជនស្តីអំពីបញ្ហានេះ គឺជាកត្តាសំខាន់ចំពោះការអប់រំកិច្ចសន្យារបស់គេព្រមទាំងរបស់យើងផ្ទាល់ដែរ ។

សង្ឃឹមថាការពិភាក្សានឹងប៉ះទៅលើវិស័យដូចជា តើអ្វីជាផលប្រយោជន៍ពិតប្រាកដនៃអនុសញ្ញាទាំងនេះ? តើគេបម្រើឱ្យគោលបំណងអ្វី? តើអ្វីខ្លះជាវត្ថុបំណងរបស់សហប្រជាជាតិ និងស្ថាប័នរបស់គេ ។ល។ បើបញ្ហាទាំងនេះ មិនបានលើកឡើងដោយក្រុមគេទាំងឡាយទេ សូមអ្នកសួរសំណួរទៅក្រុម ។ សូមបញ្ជាក់ថាអនុសញ្ញាទាំងនេះ និងការអនុវត្តរបស់វាឈរលើមូលដ្ឋានគោរពការទទួលខុសត្រូវ និងការសន្យារបស់ប្រទេសសមាជិករបស់ប្រជាជាតិ ។

បន្ទាប់មក អ្នកគួរត្រឡប់ទៅមើលអនុសញ្ញា ILO ១៨២ (ច្បាប់ចម្លងមានក្នុងកញ្ចប់) ។ អនុសញ្ញានេះត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៩, ផ្តោតលើការលុបបំបាត់រូបភាពអាក្រក់បំផុតនៃពលកម្មកុមារ ។ ដើម្បីនាំឱ្យស្គាល់អនុសញ្ញានេះគួរដកស្រង់ពីព្រឹត្តិការណ៍ដែលពលកម្មកុមារជាបញ្ហាដ៏ធំចម្បង និងថ្វីបើវត្តមាននៃអនុសញ្ញាជាអន្តរជាតិ និង នីតិកម្មជាតិក៏ដោយក៏ការរំលោភនៅតែកើតឡើង កុមារដែលកំពុងធ្វើការមានចំនួនកាន់តែច្រើន ។ ជាការពិតការពិចារណាមួយដែលប៉ះពាល់ដល់យុវជននៅក្នុងម៉ូឌុលទាំងនេះប្រសិនបើពលកម្មកុមារ គឺជាបញ្ហាចេះតែរីកធំឡើង និងមានមនុស្សដ៏ច្រើន ហើយអង្គការជាច្រើនបានរៀបចំធ្វើការប្រយុទ្ធនឹងការងាររបស់កុមារតើខ្ញុំអាចធ្វើអ្វី ? ពួកយើងចំពោះបញ្ហានេះ ។

អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

នេះជាបញ្ហាសំខាន់មួយដែលតម្រូវឱ្យអ្នកចោទសួរទៅកាន់ពួកគេយ៉ាងឆាប់ក្នុងពេលអនុវត្តម៉ូឌុលទាំងនេះ ។ សូមទាញអារម្មណ៍របស់ក្រុមឱ្យផ្តោតទៅលើក្រុមស្តីអំពីហេតុដែលធ្វើឱ្យពលកម្មកុមារបង្កើតមានបញ្ហា ទោះបីមានការប្រយុទ្ធ និងការប្រឹងប្រែងលុបបំបាត់ពលកម្មកុមារទូទាំងពិភពលោកក៏ដោយចុះ ។

នេះជាការសន្មតសម្រាប់អនុម័តអនុសញ្ញាដ៏សំខាន់នេះ ។ វាច្បាស់ណាស់រឿងដែលពលកម្មកុមារគឺជាបញ្ហាដ៏ចម្បងដែលមិនអាចពិនិត្យដោះស្រាយបាន ដោយគ្រាន់តែប្រើប្រាស់អាយុអប្បបរមាសម្រាប់បម្រើការងារឡើយ។ ដូច្នេះ អនុសញ្ញាថ្មីនេះត្រូវទទួលយកដើម្បីសាកល្បង ពិនិត្យដោះស្រាយបញ្ហាពលកម្មកុមារឱ្យបានជាក់ស្តែងដោយផ្តោត ទៅលើទម្រង់អាក្រក់បំផុតដែលមិនអាចអនុញ្ញាតិបានក្នុងនោះ មានបេស្យាកម្មកុមារ កុមារយោធា កុមារចរាចរគ្រឿងញៀន និងការងារប្រកបដោយគ្រោះថ្នាក់ ផ្សេងទៀត ។

សូមពណិនាដោយសង្ខេបអំពីរបៀបដែលអនុសញ្ញាដំណើរការ និងសង្ឃឹមដែលអាចទទួលបានដោយសារកម្មវិធីដែលកំណត់ពេលវេលាច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនគួរចំណាយពេលវែងពេកចំពោះអនុសញ្ញានេះទេ ត្រូវកំណត់ពេលសម្រាប់និយាយអំពី ទម្រង់អាក្រក់បំផុតមួយចំនួនអំពីពលកម្មកុមារ និងអំពីបញ្ហាដែលទាក់ទង នឹងបញ្ហាពលកម្មកុមារ ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សូមបញ្ជាក់ទៅក្រុមថាមានឧបករណ៍ត្រៀមបម្រុងសម្រាប់រាប់រងថាកុមារទាំងឡាយ ត្រូវបានការពារ និងបានរីករាយក្នុងវ័យកុមាររបស់គេនិងបានទទួលការអប់រំ ។ សង្គម និងយុវជនដែលធ្វើឱ្យអនុសញ្ញាត្រូវប្រើប្រាស់ និងអនុវត្តត្រឹមត្រូវពិសេសនិយោជក ត្រូវតែគោរពរក្សាទុកច្បាប់ ។ យើងមានការទទួលខុសត្រូវក្នុងយុទ្ធនាការលុបបំបាត់ពលកម្មកុមារ ។ ដូច្នេះយើងត្រូវរៀនសូត្រឱ្យបានជ្រៅជ្រះដើម្បីយកមកផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយដល់អ្នកដទៃទៀត ។

សេចក្តីប្រកាសនៃអង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋានទៅកន្លែងការងារ និងសកម្មភាពបន្ត

អត្ថបទចុងក្រោយដែលអ្នកអាចបង្ហាញទៅក្រុមគឺសេចក្តីប្រកាសរបស់ ILO អំពីគោលការណ៍ជាមូលដ្ឋាន ស្តីពីសិទ្ធិក្នុងការងារ និងការតាមដាន អនុម័តក្នុងខែមិថុនា ឆ្នាំ១៩៩៨ ។ ទោះបីសេចក្តីប្រកាសនេះមិនមានទម្រង់ ឬតួនាទីដូចអនុសញ្ញាមុនៗក៏ដោយ ។ វាជាឯកសារអន្តរជាតិយ៉ាងសំខាន់ដោយហេតុថា វាធានាកិច្ចសន្យារបស់ ILO ជាឧឡារិក និងរបស់ប្រទេសទាំងឡាយជាសមាជិកនឹងអនុវត្តគោរពតាមផ្សព្វផ្សាយ និងធ្វើឱ្យសម្រេចនូវគោលការណ៍នៃសិទ្ធិទាំងបួនដូចតទៅ :

១- សេរីភាពនៃការចូលជាសមាគមន៍ និង ការទទួលស្គាល់សិទ្ធិចរចារជាសមូហភាព (សិទ្ធិជាមូលដ្ឋានរបស់សហជីព)

២- ការលុបបំបាត់រាល់ទម្រង់នៃការងារបង្ខិតបង្ខំ (ឧទាហរណ៍ ទាសភាព)

៣- ប្រសិទ្ធភាពនៃការលុបបំបាត់ពលកម្មកុមារ (ជាគន្លឹះសំខាន់)

៤- ការលុបបំបាត់ការរើសអើងទៅលើការងារ និងមុខរបរ

សូមបញ្ជាក់ទៅលើគោលការណ៍ទីបីដែលជាការសំខាន់សម្រាប់ក្រុម ។ ប្រសិទ្ធភាពរាល់រដ្ឋជាសមាជិក (ប្រទេស) ដែលបានចូលរួមការលុបបំបាត់ពលកម្មកុមារ ។ កិច្ចសន្យានេះសម្រាប់រាល់ប្រទេសទាំងអស់ដោយមិនគិត អំពីកម្រិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច តម្លៃវប្បធម៌ ប្រវត្តិសាស្ត្រ ឬចំនួនអនុសញ្ញារបស់ ILO គេបានអនុម័ត ។ វាជាឧទាហរណ៍អន្តរជាតិតែមួយគត់ ។ គឺជួយបណ្តាប្រទេសដែលត្រូវការជំនួយក្នុងការបំពេញកិច្ចសន្យារបស់ខ្លួន ឧទាហរណ៍ កិច្ចការលុបបំបាត់ពលកម្មកុមារ ។

សូមពន្យល់ដល់ក្រុម អំពីរបៀបដែលគេធ្វើសេចក្តីប្រកាស និងការតាមដានការងាររបស់គេ ដោយប្រើឧទាហរណ៍គន្លឹះពីរៈការពិនិត្យដោយហ្មត់ចត់ឡើងវិញប្រចាំឆ្នាំគឺបានធ្វើពីរបាយការណ៍នៃបណ្តាប្រទេស ដែលមិនបានឱ្យសច្ចានុម័តទាក់ទងនឹងគោលការណ៍សំខាន់ទាំងបួន និងសិទ្ធិជាមូលដ្ឋាន ឧទាហរណ៍អនុសញ្ញាលេខ ១៣៨ និង ១៨២ ដូចបានពណ៌នាពីខាងដើម។ របាយការណ៍នេះបង្ហាញឱ្យឃើញនូវការរីកចម្រើននៃគោលការណ៍ និងសិទ្ធិជាមូលដ្ឋាន ។ ចំណុចសំខាន់មួយទៀតសម្រាប់ក្រុម

នោះគឺអង្គការពលករ និងជាអង្គការនិយោជកបានលើកទឹកចិត្តឱ្យអនុវត្តផ្នែកម្យ៉ាងសកម្មនូវវិធីសាស្ត្រមួយដោយលើកកម្ពស់សេចក្តីប្រកាសអនុសញ្ញា និងធ្វើអត្ថាធិប្បាយលើរបាយការណ៍ដើម្បីឱ្យរបាយការណ៍នោះត្រូវគេដាក់បញ្ចូលទៅក្នុងការតាមដាន ត្រួតពិនិត្យប្រចាំឆ្នាំ ។

របាយការណ៍ត្រូវនិយាយអំពីស្ថានភាពនៃការងាររបស់កុមារ ហើយក្រុមអាច ទាមទារយល់ដឹងនូវខ្លឹមសាររបស់របាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋាភិបាល ។ អ្នកអាច បង្ហាញឱ្យឃើញថាតំណាងរដ្ឋាភិបាលមានការភ្ញាក់ផ្អើលដោយសារសំណួររបស់យុវជន ហើយតំណាងនោះជួនកាលមិនអាចឆ្លើយបានផង ។ សកម្មភាពនេះរួមចំណែកនៃការរៀនសូត្រ ហើយក្រុមយុវជនពង្រឹងស្មារតីនិងតួនាទីរបស់ខ្លួនក្នុងការលើកកម្ពស់សេចក្តីប្រកាសរបស់អនុសញ្ញាគោលការណ៍ និងសិទ្ធិមូលដ្ឋានក៏ដូចជាលើកកម្ពស់យុត្តិធម៌សង្គមផងដែរ ។ យើងគ្រប់រូបសុទ្ធតែមានតួនាទីដែលត្រូវបំពេញ ។ របាយការណ៍សរុបអាចធ្វើម្តងក្នុង ១ ឆ្នាំផ្ទុយពីរបាយការណ៍ប្រចាំឆ្នាំដែលតម្រូវឱ្យរាយការណ៍ប្រភេទនីមួយក្នុងចំណោមប្រភេទទាំង ៤ នៃគោលការណ៍ និងសិទ្ធិជាមូលដ្ឋាន ។ របាយការណ៍និយាយផងដែរ អំពីរដ្ឋដែលជាសមាជិករបស់ ILO ដោយមិនគិតថារដ្ឋទាំងនោះបានឬមិនបាន អនុម័តអនុសញ្ញាទាំងឡាយឡើយ ។ ដូច្នេះក្នុងរយៈពេលបួនឆ្នាំ រាល់ប្រភេទនៃគោលការណ៍ និងសិទ្ធិជាមូលដ្ឋានទាំងឡាយនឹងបានពិនិត្យកែលម្អ ។ ក្នុងឆ្នាំ ២០០២ គឺបញ្ហាពលកម្មកុមារដែលជាកម្មវត្ថុនៃរបាយការណ៍ ។

នៅចុងបញ្ចប់នៃការពិភាក្សាក្រុមបានយល់ថាសេចក្តីប្រកាស គឺជាអន្តរជាតិដែលមានថាមពល ហើយត្រូវបានគេប្រើប្រាស់ដើម្បីពិនិត្យមើលនូវការគោរពប្រទេសជាសមាជិក ILO នូវផ្នែកទាំង ៤ នៃសិទ្ធិជាមូលដ្ឋានប្រកបដោយយុត្តិធម៌សង្គមនៅក្នុងពិភពលោក ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សម្រាប់ព័ត៌មានបន្ថែមទៀត បើអ្នកមានអ៊ីនធើណែតយើងសូមផ្តាំផ្ញើឱ្យអ្នកទៅមើលផ្នែកទាក់ទងរបស់ ILO អំពីសេចក្តីប្រកាស ។ របស់ ILO, និងតាមដានចំណងទាក់ទងទំព័ររបស់សេចក្តីប្រកាស ។

សកម្មភាព ៣ : ការប្រមូលផ្តុំរូបភាព

បច្ចៀន ១ ពេល

នេះជាលំហាត់មួយពោរពេញដោយសកម្មភាពដែលមានឥទ្ធិពលទៅវិញទៅមកដែលជួយក្រុមឱ្យយល់ចំណុច សំខាន់ជាគន្លឹះនៃអនុសញ្ញាខាងលើរូបភាពប្រមូលផ្តុំ ។ លំហាត់នេះអាចដឹកនាំអ្នកឱ្យស្គាល់អនុសញ្ញា ឬអាចបន្ថែមអ្វីដែលអ្នកបានធ្វើរួចហើយ ។

អ្នកត្រូវការរៀបចំសម្ភារសម្រាប់លំហាត់នេះជាមុន ។ ដំបូងបង្អស់ ក្តារខៀន ខ្មៅ/ស ក្រដាសធ្ងាំងធំ ឬក្រដាសធំបិទលើជញ្ជាំងចម្ងងចំណុចសំខាន់ជាគន្លឹះ និងសេចក្តីថ្លែងការណ៍ចេញពីអនុសញ្ញាទាំងបីដែលអាននៅទីនេះ អនុសញ្ញារបស់សហប្រជាជាតិស្តីអំពីសិទ្ធិ របស់កុមារ និងអនុសញ្ញារបស់ ILO លេខ ១៣៨ និងលេខ ១៨២ ។ ឧទាហរណ៍ "របស់រដ្ឋទទួលស្គាល់សិទ្ធិ ទទួលការអប់រំរបស់កុមារ" ឬ" របស់រដ្ឋទទួលស្គាល់សិទ្ធិទទួលការការពាររបស់កុមារឱ្យផុតពីការធ្វើអាជីវកម្មសេដ្ឋកិច្ច" សូមសរសេរឱ្យបានច្បាស់ដើម្បីក្រុមទាំងអស់អានសេចក្តីថ្លែងនោះ វាជាការសំខាន់ដែលអ្នកប្រើប្រាស់ឃ្លាខ្លី ៗ និងកុំចម្ងងចេញនូវសេចក្តីដកស្រង់ច្បាប់ដែលវែងពេក ។

បន្ទាប់មក ប្រើប្រាស់ប្រភពផ្សេងៗ ដែលអាចរកបានចំពោះអ្នក (មើលម៉ូឌុលរូបភាព) ជ្រើសរើសជាបន្តបន្ទាប់នៃរូបភាពថត-ឬអ្វីដែលបោះពុម្ព, ដែលអ្នករកឃើញក្នុងការបោះពុម្ពផ្សព្វផ្សាយស្បៀវភៅសន្លឹកប័ណ្ណ។ សូមជ្រើសរើសរូបភាពកុមារមួយចំនួន ដែលត្រូវបានគេធ្វើអាជីវកម្មធ្វើទុក្ខទោស ឬបំបាត់សិទ្ធិរបស់គេតាមមធ្យោបាយមួយចំនួន ។ ក្នុងចំណោមរូបទាំងនេះមានពលកម្ម, អ្នកផ្សេងទៀតជាកុមារអនាថាតាមដងផ្លូវ ឬកុមារខ្វះជីវជាតិអាហារ ។ ទោះបីអ្នកជ្រើសរើសរូបភាពច្រើនបំផុតមកផ្សំគ្នានឹងសេចក្តីថ្លែងទាំងឡាយដកស្រង់ចេញពីអនុសញ្ញាទាំងបីក៏ដោយ អ្នកត្រូវរករូបភាពពីប្រភពផ្សេងៗដែលពណ៌នាពីការរំលោភសិទ្ធិមនុស្ស។ ឧទាហរណ៍អ្នកណាម្នាក់ត្រូវវាយដោយប៉ូលីស មនុស្សគ្មានផ្ទះសម្បែង អ្នកភៀសខ្លួនត្រូវគេចាប់ ស្ត្រីត្រូវគេរើសអើង ។ល។ រូបភាពនេះត្រូវយកទៅប្រើប្រាស់ ក្នុងការពិភាក្សាបញ្ចប់លំហាត់នេះ ។

សូមលាតត្រដាងរាល់រូបភាពដែលទាក់ទងទៅនឹងអនុសញ្ញានៅលើតុជិតកន្លែងដែលអ្នកបានសរសេរសេចក្តីថ្លែងការណ៍ ។ ហៅក្រុមដែលជាបុគ្គលឱ្យមកសិក្សាសេចក្តីថ្លែងការផ្សំនឹងរូបភាព ។ ហៅពួកគេមកជ្រើសរើសរូបភាពណាមួយ មកដាក់ផ្សំរំលេចសេចក្តីថ្លែងការណ៍ក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងឡាយម្នាក់ម្តងនៅពេលចន្លោះការពិភាក្សា ។ ឧទាហរណ៍ សមាជិកម្នាក់នៃក្រុមអាចនឹងជ្រើសរើសរូបភាពមួយនៃកុមារកំពុងធ្វើការងារក្នុងរោងចក្រកម្រាលព្រំ ហើយភ្ជាប់រូបភាពនោះទៅនឹងសេចក្តីថ្លែងការណ៍ពោលថា " រដ្ឋទទួលស្គាល់សិទ្ធិរបស់កុមារ-កុមារត្រូវបានការពារទប់ទល់នឹងអាជីវកម្មសេដ្ឋកិច្ច" ។

ហៅបុគ្គលម្នាក់ៗ ដែលបានភ្ជាប់រូបភាពណាមួយទៅនឹងសេចក្តីថ្លែងការណ៍ឱ្យមកពន្យល់ហេតុអ្វីបានជាគេជ្រើសរើសរូបភាពនោះ ។ សូមសួរទៅក្រុមថាតើពួកគេទាំងអស់គ្នាយល់ព្រមជាមួយការជ្រើសរើសនេះ ឬទេ? ។ តើមានអ្នកណាចង់ជ្រើសរើសរូបភាពផ្សេងៗឬទេ ? ត្រូវសួរជាថ្មីម្តងទៀត ហេតុអ្វីបានជាគេជ្រើសរើសយករូបភាពនេះ ? ត្រូវហៅពួកគេឱ្យពន្យល់បកស្រាយតម្រូវតាមមូលហេតុពិសេស ត្រូវសួរពួកគេថាតើអ្នកយល់ដឹងអ្វីខ្លះអំពីពាក្យ "សិទ្ធិ"? ។ តើយីគេគិតថាសិទ្ធិជាអ្វីទៅ? តើសិទ្ធិត្រូវគេអនុវត្តដូចម្តេចចំពោះប្រជាជនក្នុងសង្គម ប្រជាជននៅតាមថ្នល់គេទាំងនោះជាយុវជន ? សូមញុំងការពិភាក្សានេះដោយធ្វើឱ្យមានចំណាប់អារម្មណ៍ឱ្យរស់រើក ។ រាល់សេចក្តីថ្លែងការណ៍ដែលបានសរសេររួច ត្រូវមានយ៉ាងហោចណាស់រូបភាពមួយមកភ្ជាប់ រូបភាពមួយអាចយកទៅភ្ជាប់ច្រើនដងជាមួយនឹងសេចក្តីថ្លែងការណ៍ផ្សេងទៀតវាមិនជាអ្វីទេ ។ ជាការសំខាន់គឺក្នុងរយៈពេលពិភាក្សាអ្នកត្រូវ ចេះធ្វើឱ្យទំនាក់ទំនងគ្នារវាងសិទ្ធិនិងសិទ្ធិទៅតាមនិយមន័យកំណត់ក្នុងអនុសញ្ញាអន្តរជាតិ និងក្នុងប្រទេសមានប្រព័ន្ធច្បាប់ត្រឹមត្រូវ ។ ដើម្បីឱ្យអត្ថន័យនៃសិទ្ធិក្នុងអនុសញ្ញាអនុវត្តបានត្រឹមត្រូវក្នុងប្រទេសមួយ។ ប្រទេសនោះត្រូវបញ្ចូលអនុសញ្ញានោះទៅក្នុងច្បាប់របស់គេ ។ ដោយសារអនុសញ្ញានេះ ប្រជាពលរដ្ឋអាចត្រូវបានការពារតាមផ្លូវច្បាប់ និងត្រូវបានការពារប្រសិនបើសិទ្ធិរបស់វា ត្រូវបានរំលោភ ឬបំពាន ដោយប្រការណាមួយ។ ចំពោះសិទ្ធិរបស់កុមារដែរក៏ត្រូវអនុវត្តដូចរបៀបនេះដែរ។



នៅពេលដែលការពិភាក្សាជិតបញ្ចប់ សូមយកចេញរូបភាពផ្សេងៗទៀត ដែលអ្នកបានរកឃើញអំពីការរំលោភផ្សេងៗទៀតនៃសិទ្ធិ ។ ហុចបន្តរូបភាពទាំងនេះក្នុងចំណោមក្រុមរួចសួរគេថាសិទ្ធិដែលត្រូវបានរំលោភក្នុងរូបភាពនេះសិទ្ធិអ្វី?សុំឱ្យពិភាក្សាអំពីការរំលោភ។ រូបភាពមួយចំនួននោះមិនគួរឱ្យក្រុមមើលឃើញទេ ដែលធ្វើឱ្យក្រុមជាឧទាហរណ៍ ស្តីពីការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ បញ្ហាការរើសអើង គឺសំខាន់ពិសេសការធានាសិទ្ធិនៃមនុស្សគ្រប់រូបក្នុងសង្គម និង វាអាចនាំទៅរកផលប្រយោជន៍សំខាន់មួយចំនួនអំពីការពិភាក្សាជាមួយក្រុមរបស់អ្នក ពិសេសប្រសិនបើអ្នកស្ថិតក្នុងសង្គមពហុជាតិ ។

ត្រូវតម្រង់ទិសការពិភាក្សាឱ្យទៅរកវប្បធម៌ដែលរដ្ឋាភិបាល និងសង្គមទូទៅត្រូវបានប្រើដើម្បីទប់ទល់រាល់ការរំលោភ ។ តើត្រូវធ្វើដូចម្តេចដើម្បីរ៉ាប់រងសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនដែលមិនត្រូវបានរំលោភ និងតើម្នាក់ៗអាចត្រូវបានការពារយ៉ាងដូចម្តេច ? មិនតែប៉ុណ្ណោះ, ទាំងអស់គ្នាគួរត្រូវបានការពារឬទេ ? តើក្រុមមានអារម្មណ៍ថាអ្នកទាំងអស់គ្នា មិនគួរត្រូវបានការពារឬមិនគួរមានសិទ្ធិអ្វីទេ? តើគេជានរណា និងហេតុអ្វីបានជាគេគិតដូច្នោះ ?

ដូចបានថ្លែងរួចមកហើយការភ្ជាប់អនុសញ្ញាបានអនុម័តដោយអង្គការអន្តរជាតិទាំងឡាយដូចជាសហប្រជាជាតិ ទៅនឹងច្បាប់របស់ប្រទេសផ្ទាល់ខ្លួន គឺសំខាន់ណាស់។ ដោយសារអនុសញ្ញាអន្តរជាតិទាំងនេះ ច្បាប់របស់ប្រទេសនីមួយៗអាចត្រូវបានកែលម្អដើម្បីរ៉ាប់រងកិច្ចការពារសិទ្ធិមនុស្សឱ្យប្រសើរឡើង។ តាមរយៈអនុសញ្ញាអន្តរជាតិទាំងនេះផងដែរ សហគមន៍អន្តរជាតិអាចសម្តែងចេញការមិនសប្បាយចិត្តរបស់ខ្លួនចំពោះអាកប្បកិរិយាមិនល្អរបស់ប្រទេសណាមួយ ដែលមានការរំលោភសិទ្ធិមនុស្សព្រមទាំងព្យាយាមបំបាត់ការរំលោភសិទ្ធិនោះ។

អនុសញ្ញាអន្តរជាតិជាឧទាហរណ៍សំខាន់ណាស់ និងបម្រើនូវបំណងដ៏ចាំបាច់ក្នុងការការពារមនុស្ស, ជាពិសេស អ្នកដែលងាយរងគ្រោះក្នុងសង្គមដូចជាកុមារជាដើម ។

សកម្មភាព ៤: ការកាត់រូបចេញពីសារព័ត៌មាន

បង្ក្រៀនមួយពេល ឬច្រើនពេល

លំហាត់ពិសេសនេះអាចធ្វើនៅពេលណាក៏បាន ចំពោះក្រុមរបស់អ្នក ។ គេអាចធ្វើនៅពេលចាប់ផ្តើមនៃគម្រោង និង បន្តក្នុងការអនុវត្តន៍ម៉ូឌុល ។ ឧទាហរណ៍, ប្រសិនបើ អ្នកបានចាប់ផ្តើមគម្រោងរបស់អ្នកជាមួយនឹងម៉ូឌុលបិទក្រដាស។ អ្នកត្រូវឱ្យគេគិតថែមទៀតអំពីបញ្ហាកុមារពលកម្ម និងការខ្វះខាតអំពីអ្វីសម្រាប់ផ្សព្វផ្សាយ ។ នេះគឺជាជំហានមួយ ត្រឹមត្រូវដើម្បីលើកទឹកចិត្តពួកគេឱ្យតាមដានរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយកាន់តែជិតដល់ និងកត់ត្រាអ្វីដែលការពិភាក្សាអំពីកុមារពលកម្ម ឬអំពីបញ្ហាដែលពាក់ព័ន្ធ ។ អ្នកគួរលើកទឹកចិត្តក្រុមឱ្យស្វែងយល់ដឹងថែមទៀតអំពីអ្វីដែលកើតឡើងក្នុងពិភពលោកជុំវិញខ្លួនគេ និងយកចិត្តទុកដាក់ទាញយកផលប្រយោជន៍ក្នុងបញ្ហាបែបនេះ ។

គោលបំណងនៃលំហាត់គឺលើកទឹកចិត្តក្រុម ឱ្យពិនិត្យមើលតាមរយៈសំណេរផ្សព្វផ្សាយ, ដូចជាសារព័ត៌មាន និងទស្សនាវដ្តី ដើម្បីរកអត្ថបទស្តីអំពីពលកម្មកុមារ ឬបញ្ហាពាក់ព័ន្ធ ។ ទោះបីព័ត៌មានអំពីពលកម្មកុមារមិនបានលាតត្រដាង ក្នុងឧបករណ៍ផ្សព្វផ្សាយក៏ដោយ ក្រុមត្រូវតែចាប់ផ្តើមអត្ថបទដែលនិយាយអំពីបញ្ហានេះនៅក្នុងអត្ថបទសារព័ត៌មានខ្លះ។គេគួរកាត់យកអត្ថបទទាំងនេះរៀបចំឯកសារផ្ទាល់ខ្លួនរបស់គេ ដែលគេអាចបន្ថែមទៅលើទិន្នន័យព័ត៌មានដែលត្រូវបានកសាងតាមរយៈលំហាត់ផ្សេងៗទៀត ។

លំហាត់កាត់រូបចងក្រងជាឯកសារ គឺជាលក្ខណៈងាយស្រួលជាទីបំផុត។ ជាការបន្តទៅទៀត គេអាចធ្វើក្នុងក្រុមធំក៏បាន ឬ ក្នុងក្រុមតូចៗក៏បាន ។ វាអាស្រ័យតែលើអ្នកសម្រេចថាតើ វានឹងមានផលប្រយោជន៍ច្រើនដល់អ្នករាល់គ្នាក្នុងក្រុមឬទេ ? សមាជិកក្រុមខ្លះមាន និន្នាការថតចម្លងរូបក្នុងសារព័ត៌មាន ទស្សនាវដ្តីយកទៅចុះក្នុងអត្ថបទផ្សព្វផ្សាយ។ ប៉ុន្តែ តាមការពិតមិនមានន័យដើមពាក់ព័ន្ធទៅនឹងបញ្ហាពលកម្មកុមារឡើយ។ ក្នុងខណៈដែលអនុញ្ញាតឱ្យមានសេរីភាព (ក្នុងការអានកាសែតជាដើម) នោះអាចធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងទូទៅរបស់យុវជន ចូរយើងធានាថាក្រុម និង



បុគ្គលទាំងឡាយបានចងចាំអំពីការងារផង ដែរនៅក្នុងកណ្តាប់ដៃរបស់គេផង ។

សូមអនុវត្តលំហាត់ទាំងនេះកុំឱ្យលើសមួយដងក្នុងមួយសប្តាហ៍ ដើម្បីធានាថាវានឹងមានការសែតគ្រប់គ្រាន់ជានិច្ច និងទស្សវដ្តីដែលអាចរកបាន សម្រាប់គ្រប់ក្រុមទុកជាប្រយោជន៍របស់គេ ។ សូមលើកទឹកចិត្តសមាជិកក្រុមឱ្យយកការសែតចូល និងទស្សវដ្តីមកជាមួយគេ មិនថាយកមកពីផ្ទះ មកពីហាងក្នុងស្រុក ឬពីភ្នាក់ងារសារព័តមាន ដែលហួសសម័យក៏ដោយ ។

អ្នកជំនួញក្នុងស្រុកភាគច្រើនបំផុតអាចឆ្លើយតបជាវិជ្ជមានចំពោះតម្រូវការ និង អាចធ្វើឱ្យប្រសើរឡើង នូវដំណើរការបញ្ចូលសហគមន៍ ។

សូមសាកល្បង និងរក្សាភាពស្ងប់ស្ងាត់ប្រកបដោយបរិយាកាសល្អនៅពេលដឹកនាំលំហាត់កាត់រូបភាពចងក្រងជាឯកសារ ។ សូមដើរជុំវិញក្រុម និងបុគ្គលហើយនិយាយទៅកាន់គេពេលដែលគេពិនិត្យមើលសម្ភារ ។ ប្រសិនបើអ្នកមានឱកាសពិនិត្យមើលសម្ភារដោយផ្ទាល់ជាមុន សូមកត់ត្រាអត្ថបទដែលពាក់ព័ន្ធ ហើយតម្រង់ទិសក្រុមឆ្ពោះទៅអត្ថបទទាំងនេះ ។ មានការលើកទឹកចិត្ត ជំរុញឱ្យមានទំនាក់ទំនងរវាងបុគ្គល និង បុគ្គលនៅក្នុងក្រុមគេត្រូវសម្រេចចិត្តយកអត្ថបទពាក់ព័ន្ធឬមិនពាក់ព័ន្ធទៅនឹងបញ្ហានៃពលកម្មកុមារ ។ លំហាត់បញ្ហានេះនឹងធ្វើឱ្យការយល់ដឹង អំពីបញ្ហាកុមារពលកម្មកាន់តែស៊ីជម្រៅឡើង ។

សូមរៀបចំលំហាត់នេះឱ្យខ្លីព្រោះការចាប់អារម្មណ៍របស់ក្រុមតែងតែមានកម្រិត ជាពិសេសបើមិនមានអត្ថបទស្របតាមតម្រូវការទេនោះ ។ អ្នកកត់សម្គាល់ថាពួកគេមិនធ្វើការស្រាវជ្រាវបន្តទៀតទេហើយពួកយកចិត្តទុកដាក់ទៅលើទំព័រផ្សេងៗទៀត, ដូចជាផ្នែកកីឡា, ជាដើម។ អ្នកត្រូវចាប់ផ្តើមសង្ខេបលំហាត់ និងរៀបចំការប្រជុំជាថ្មី ។ ក្នុងរយៈពេលដ៏ខ្លីនេះអ្នកត្រូវស្នើរទៅក្រុម ឬបុគ្គលដែលបានកាត់អត្ថបទចេញមកឱ្យគេពន្យល់ថា តើវាមានការទាក់ទងនឹងពលកម្មកុមារ ឬទេ ? សូមលើកទឹកចិត្តអ្នកដទៃទៀតឱ្យលើកសំណួររៀងៗខ្លួន ។ ការសង្ខេបត្រូវតែខ្លីហើយឆាប់រហ័ស កាលណាការចាប់អារម្មណ៍កាន់តែតិចទៅពីអត្ថបទណាមួយ,នោះប្តូរទៅអត្ថបទមួយទៀតយ៉ាងឆាប់រហ័ស។ ប្រសិនបើត្រូវពិនិត្យ"រូបចងក្រង" នោះ



ឡើងវិញ។ ត្រូវធានាថាក្រុមនីមួយៗបានរៀបរូបរាតាមលំដាប់បានល្អសមរម្យហើយឬនៅ ? យើងផ្តល់អនុសាសន៍ដល់អ្នកកាត់រូបចងក្រងឯកសារ ត្រូវតែមានការគាំទ្រពីក្រុមទាំងអស់ ដើម្បីឱ្យគេរាល់គ្នាអាចទទួលព័ត៌មានក្នុងរយៈពេលនៃការស្រាវជ្រាវរបស់គេ។ អ្នករៀបចំចងក្រងរូបជាឯកសារអាចជួយ ដល់ម៉ូឌុលផ្សេងទៀត ឧទាហរណ៍ កិច្ចពិភាក្សាដែលនៅក្នុងនោះការស្រាវជ្រាវដើរតួនាទីសំខាន់ ។ សូមលើកទឹកចិត្តក្រុមមានទម្លាប់អានកាសែត និងទស្សនាវដ្តីនៅផ្ទះ ស្តាប់វិទ្យុ និង/តាមដានព័ត៌មានក្នុងទូរទស្សន៍ ប្រសិនបើឧបករណ៍ផ្សព្វផ្សាយទាំងនេះអាចរកបាន ។

សូមពន្យល់ទៅយុវជនថា បើប្រជាជនក្នុងពិភពលោកមិនយកចិត្តទុកដាក់ចំពោះអ្វីដែលកើតឡើងក្នុងកន្លែងផ្សេងទៀតទេ បាតុភូតអាក្រក់ដូចពលកម្មកុមារនឹងកាន់តែអាក្រក់ និងការធ្វើអាជីវកម្មលើកុមារកើនឡើង ។ លំហាត់កាត់រូបភាពចងក្រងជាឯកសារគឺងាយហើយមានតម្លៃថោក ប៉ុន្តែវានឹងជំរុញឱ្យយុវជនយល់ដឹងអំពីអ្វីកើតឡើងក្នុងពិភពលោក ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ប្រសិនបើអ្នកដឹកនាំម៉ូឌុលទាំងនេះ ធ្វើការអប់រំក្នុងប្រព័ន្ធ ហេតុដូចម្តេចបានជាមិនប្រមើលលទ្ធភាពបញ្ចូលវិស័យផ្សេងទៀតក្នុងការអប់រំផង ។ ឧទាហរណ៍ ប្រសិនបើសាលាមានកម្មវិធីផ្សព្វផ្សាយរបស់គេ យើងគួរតែចូលទៅទាក់ទងគ្រូបង្រៀននៃកម្មវិធីនេះដើម្បីបញ្ចូលលំហាត់ កាត់រូបសារព័ត៌មានទៅក្នុងក្រុមសិស្សក្នុងប្រព័ន្ធនោះ ។ ប្រសិនបើមិនមានគ្រូដោយឡែកសម្រាប់បង្រៀនអំពីប្រព័ន្ធផ្សព្វផ្សាយទេនោះ សូមទាក់ទងជាមួយនឹងបុគ្គលសិក្សាដែលបង្រៀនមុខវិជ្ជាផ្សេងទៀត ។

សកម្មភាព ៥: ការស្រាវជ្រាវ

បច្ចៀន ២ ពេល

សកម្មភាពជាដំបូងៗក្នុងម៉ូឌុលនេះតម្រូវឱ្យអ្នកនិយាយបានទូលំទូលាយ។ ប៉ុន្តែពេលនេះត្រូវណែនាំក្រុមឱ្យធ្វើការងារ មួយ អ្នកមិនត្រូវចំណាយពេលច្រើន ដើម្បីនិយាយ "ទៅកាន់" ក្រុមទេ។ ត្រូវប្រយ័ត្នកុំឱ្យរឿងនេះកើតឡើង។

អនុសញ្ញាសហប្រជាជាតិនិង ILO សំខាន់និងចាំបាច់ណាស់ ។ ក្រុមយុវជនត្រូវយកចិត្តទុកដាក់អំពីទិដ្ឋភាពនៃយុទ្ធនាការលុបបំបាត់ទាំងស្រុងពលកម្មកុមារ ។ តាមរយៈអនុសញ្ញាទាំងឡាយនេះគម្រោងមាននៅក្នុងបរិបទ ។ គម្រោងនេះនឹងជួយពួកគេឱ្យយល់កាន់តែប្រសើរឡើងនូវមូលហេតុដែលនាំឱ្យពួកគេធ្វើសកម្មភាពទាំងនេះ ។ ពីពេលនេះតទៅ វានឹងមានព័ត៌មានផ្សេងៗទៀតយ៉ាងច្រើនស្តីអំពីបញ្ហានេះ ហើយជំរុញពួកគេឱ្យធ្វើការស្រាវជ្រាវ និងក្លាយជាអ្នកទទួលខុសត្រូវ ។ អ្នកអាចបានទទួលសម្ភារពី IPEC ឬអង្គការផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងពលកម្មកុមារ ។ អ្នកអាចបញ្ចុះបញ្ចូលឱ្យមានការគាំទ្រអំពីបណ្ណាល័យដើម្បីស្គាល់អត្តសញ្ញាណនៃឯកសារយោង ហើយ ដាក់ឯកសារ ឬសម្ភារនោះទៅឱ្យក្រុមប្រើប្រាស់ ។ អ្នកអាចប្រើប្រាស់អ៊ីនធើរណែត ។ អ្នកអាចមានព័ត៌មានអំពីសហជីព និងអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ។ អ្នក អាចទាញយកប្រយោជន៍បានពេញលេញពីធនធានទាំងនោះ ។ ត្រូវពិចារណាអំពីការងារមួយចំនួនសម្រាប់ក្រុម ដើម្បីលើកទឹកចិត្តគេទាំងនោះឱ្យដឹកនាំការស្រាវជ្រាវរបស់គេផ្ទាល់ ។ ត្រូវផ្តល់ឱ្យនូវបញ្ជីប្រភពសម្ភារមួយចំនួនក្នុងនោះមានវែប សាយដែលនឹងជួយការងាររបស់ពួកគេ ។ បើសិនជាចាំបាច់, ផ្តល់ដល់ក្រុមនូវការបណ្តុះបណ្តាលមូលដ្ឋានអំពីការស្រាវជ្រាវតាមអ៊ីនធើណែតទៅតាមប្រធានបទនិងឈ្មោះ។ ប្រហែលជាបណ្ណា រក្សនឹងធ្វើកិច្ចការនេះ ឬក៏គ្រូដែលទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន ។

ស្រាវជ្រាវតាមវិបសាយ

រៀបចំជាក្រុមតូចៗមានគ្នា ៣ឬ ៤ នាក់។ ការចាត់តាំងពួកគេឱ្យស្រាវជ្រាវរកចំនួនវែបសាយ ៣ នាក់ក្នុង ១ ក្រុមស្តីអំពីការងាររបស់កុមារ ។ មិនត្រឹមតែ

ស្វែងរកអាស័យដ្ឋានវិបសាយប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវផ្តល់សង្ខេបខ្លឹមរបស់វែបសាយ ។ រៀបចំចាត់ចែងដើម្បីគ្រប់គ្រងការងារសកម្មភាពរបស់ពួកគេ ។

ដើម្បីសរសេររបាយការណ៍សង្ខេបមួយ, ក្រុមត្រូវពិនិត្យមើលវែបសាយដោយប្រុងប្រយ័ត្ន ។ ក្រុមនីមួយៗ ត្រូវសង្ខេបសេចក្តីដោយលាយល័ក្ខអក្សរ ។ បន្ទាប់មក អ្នកគួរធ្វើការប្រជុំមួយក្នុងនោះក្រុមនីមួយៗ ត្រូវមានសេចក្តីសង្ខេបរបស់ខ្លួនមួយឱ្យឮខ្លាំង ។ អ្នកស្នើដល់ក្រុមឱ្យជ្រើសរើសបុគ្គលណាមួយឬក្រុមណាមួយ (ដំណើរទាំងនេះត្រូវតែស្ថិតក្នុងលក្ខណៈប្រជាធិបតេយ្យ) ដើម្បីកត់ត្រារាល់ការអានរបាយការណ៍ចូលក្នុងឯកសារ។ ដែលបន្ទាប់មកកំណត់ត្រានេះអាចថតចម្លងសម្រាប់ចែកជូនដល់អ្នករាល់គ្នា ហើយវាជាលទ្ធផលនៃការស្រាវជ្រាវ ។

បង្កើតសន្លឹកព្រឹត្តិការណ៍មួយ

ចាត់តាំងក្រុមតូចៗ ឬបុគ្គលឱ្យបង្កើតសន្លឹកព្រឹត្តការណ៍របស់គេផ្ទាល់ដោយស្រង់ចេញអំពីមូលដ្ឋានណាមួយក៏បាន ពីព័ត៌មានរកឃើញក្នុងវែបសាយ ឬក្នុងអត្ថបទណាមួយក៏បាន ។ សន្លឹកព្រឹត្តិការណ៍គួរមាន ១០ ព្រឹត្តការណ៍ជាមូលដ្ឋានអំពីពលកម្មកុមារ ។ ក្រុមអាចដាក់បញ្ចូលនូវស្ថិតិសំខាន់ៗ ឬសកម្មភាពដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល ។ រឿងសំខាន់គឺក្រុមត្រូវបង្កើតសន្លឹកព្រឹត្តការណ៍របស់ខ្លួនផ្ទាល់ និងកត់ត្រាទីកន្លែងដែលគេបានរកឃើញព័ត៌មាន ។ ក្នុងសម័យប្រជុំ, អ្នកអាចស្នើដល់ក្រុមនីមួយៗ ឬបុគ្គលឱ្យអានឮៗនូវព័ត៌មាន ឬក្រុមទាំងអស់ស្តាប់ ។

ជាថ្មីម្តងទៀត, លទ្ធផលត្រូវសរសេរចូលក្នុងឯកសារតែមួយសម្រាប់ចែកឱ្យក្រុមទាំងមូល ។

អ្នកអាចពង្រីកកិច្ចការផ្សេងៗទៀតដូចគ្នា ដែលនឹងត្រូវលើកទឹកចិត្តក្រុមឱ្យស្រាវជ្រាវរកព័ត៌មានមូលដ្ឋានស្តីពីពលកម្មកុមារ ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ត្រូវចងចាំបេសកកម្ម និងភារកិច្ចប្រគល់ឱ្យសម្រាប់យុវជនក្នុងបរិបទនៃគម្រោង។ អ្នកមិនត្រូវបានវាយតម្លៃទេ គឺអ្នកមិនអាចប្រៀបធៀបកិច្ចការរបស់មនុស្សម្នាក់ទៅនឹងកិច្ចការរបស់មនុស្សម្នាក់ទៀតបានទេ ។ រឿងនេះមិនមែន ជាវិញ្ញាសាតែស្តេទេ ។

នេះគឺជាបំណងក្នុងការលើកកម្ពស់នៃការទទួលខុសត្រូវ និងធ្វើឱ្យអំណាចរបស់យុវជន មានដំណើរការសំខាន់ គឺយុវជនចាប់ផ្តើមចាត់ទុកជារបស់ខ្លួនឯងផ្ទាល់នូវគម្រោងទាំងឡាយ ។ ការបង្កើតឱ្យមាន និងពង្រឹងសេចក្តីទុកចិត្ត ក្នុងការបង្កើតឱ្យមានទំនាក់ទំនងគ្នា ទាំងអស់នេះជាទិដ្ឋភាពសំខាន់បំផុតនៃមេរៀន (សៀវភៅនេះ) ។

អ្វីដែលត្រូវធ្វើ និង មិនត្រូវធ្វើ



- ត្រូវប្រាកដថា បុគ្គលនីមួយៗបានចូលរួមរាល់សម័យប្រជុំនៃម៉ូឌុលនេះ ។
- ប្រើការកំប្លែងខ្លះ និងនិយាយលេងសើចជាមួយក្រុម ដើម្បីញុំាងសម័យប្រជុំឱ្យរីករាយឧស្សាហ៍ព្យាយាម ។
- លើកទឹកចិត្តបុគ្គលទាំងឡាយឱ្យកត់ត្រាដោយខ្លួនគេ និងដើរតួជាអ្នករាយការណ៍បន្ទាប់ពីបានចំណុចសំខាន់ៗក្នុងពេលពិភាក្សា ។ នេះជាបទពិសោធន៍ និងជាបច្ចេកទេសសម្រាប់យុវជនរៀនសូត្រ ។ វានឹងអប់រំបានល្អទាញយកផលប្រយោជន៍ពីរឿងនោះ ។

- កត់ត្រាដោយផ្ទាល់នូវចំណុចសំខាន់ៗដែលលើកឡើងដោយក្រុមនិងដោយបុគ្គល ។ វាអាចជាលំហាត់មួយដែលមានប្រយោជន៍ណាស់នាំឱ្យពួកអ្នកចេះកត់ត្រាផ្នែកសំខាន់ៗនៃការពិភាក្សា ។ IPEC អាចស្វាគមន៍ចំពោះរបាយការណ៍ទាំងនេះព្រោះវាអាចជួយរក្សាទុកម៉ូឌុលឱ្យបានល្អតាមលំដាប់លំដោយ និងរកឃើញប្រធានបទថ្មីៗដែលអាចទាក់ទាញយុវជន ។
- ករណីកុំបង្កលក្ខណៈក្នុងម៉ូឌុលនេះអាចមានការប្រកួតប្រជែងគ្នាទោះជាយ៉ាងណាក៏ដោយ ។ មិនត្រូវបង្កើតឱ្យមានការប្រៃស្រាំនៅក្នុងក្រុមរវាងបុគ្គល និងបុគ្គលឡើយ ។ ដូច្នេះដើម្បីកុំឱ្យអន្តរាយដល់ដំណើរការងារ ត្រូវបង្កលក្ខណៈឱ្យមានទំនាក់ទំនងគ្នារឹងមាំហើយទុកចិត្តគ្នាទៅវិញទៅមក ។

- ត្រូវធានាថាសេចក្តីដកស្រង់រាល់កិច្ចការ ត្រូវបានអានឱ្យឮខ្លាំងៗដោយមិនមែនតែកិច្ចការដែលអ្នកចាត់ទុកថាល្អបំផុតនោះទេ ។ ការងារ និងមតិរបស់ម្នាក់ៗ គឺជាការសំខាន់ ហើយអ្នកត្រូវបានមើលឃើញថា ត្រឹមត្រូវដោយមិនបានធ្វើការវិនិច្ឆ័យអ្វីឡើយ ។
- ត្រូវធ្វើការប្រជុំពិភាក្សាបញ្ចប់ដើម្បី អនុញ្ញាតឱ្យក្រុមសម្តែងមតិរបស់គេបានទូលំទូលាយ និងដោយសេរី ។ ទាំងនេះជាលំហាត់ដ៏ "លំបាក" ហើយចាំបាច់ត្រូវផ្តល់ឱ្យក្រុមនូវឱកាសបរិបូរណ៍ ដើម្បីឱ្យគេបញ្ចេញមតិដោយសេរី ។

ការពិភាក្សាបញ្ចប់

បទឆ្លៀនមួយពេល



អាស្រ័យលើក្រុមយុវជន ដែលអ្នកធ្វើការជាមួយនោះ, មានការពិភាក្សា ស្តីពី"សេរីភាពនៃការជ្រើសរើស" អាចពិតជាមានប្រយោជន៍ និងផ្តល់នូវព័ត៌មានយ៉ាងច្រើន ។ ការពិភាក្សានេះត្រូវបានចាត់ទុកជាសម័យប្រជុំអំពីមេរៀនថ្មីនេះ ។ ក្នុងប្រទេសជាច្រើន, យុវជនអាចធ្វើទម្រង់ការងារណាមួយ ដែលការងាររបស់គេ មានការងារផ្ទះការងារកសិដ្ឋានក្នុងគ្រួសារ ឬការងារជំនួញក្នុងគ្រួសារ ការធ្វើការងារម្តងម្កាលនៅពេលល្ងាចឬនៅថ្ងៃសម្រាកធ្វើការបន្តិចបន្តួចដើម្បីបានប្រាក់ចូលហោប៉ៅផ្ទាល់របស់គេ, ឬធ្វើការដើម្បីជួយគាំទ្រគ្រួសារតាមមធ្យោបាយមួយចំនួន ។ ជាការសំខាន់ គឺអ្នកត្រូវចាប់អារម្មណ៍ចំពោះស្ថានភាព ដែលប៉ះពាល់ដល់សិស្សខ្លះក្នុងចំណោមសិស្សរបស់គេ ។

ត្រូវជំរុញឱ្យមានការពិភាក្សាអំពីអ្វីដែលនៅក្រៅគម្រោង ឬក្រៅការអប់រំក្នុងប្រព័ន្ធរបស់គេ ។ តើគេលេងកីឡាឬទេ ? តើកីឡាអ្វី ? តើកីឡាទាំងអស់លួយ៉ាងដូចម្តេចដែរ ? តើគេមានល្បែងកំសាន្ត ឬមានភាពខ្ជិលច្រអូស ? តើគេជាសមាជិកនៃក្លឹបឬ ? តើគេចូលចិត្តអានឬទេ ? នាំគេនិយាយថែមទៀតអំពីបញ្ហាទាំងនេះ ។ នោះគេនឹងស្ងប់ស្ងាត់ក្នុងអារម្មណ៍ ហើយបង្កើតបរិយាកាសមួយជាវិជ្ជមានក្នុងការប្រជុំពិភាក្សា ។

កំណត់សម្គាល់

សម្រាប់អ្នកប្រើប្រាស់

ប្រភពសំខាន់នៃព័ត៌មានស្តីពីសិទ្ធិរបស់យុវជន ត្រូវបានដាក់ដម្កល់ក្នុងច្បាប់ការងាររបស់ជាតិ ស្តីការពាណិជ្ជកម្ម និងសហគ្រាស, ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និងអង្គការសហជីព ។ សូមទាក់ទងជាមួយមន្ត្រីការិយាល័យទាំងនេះ និងព្យាយាមយល់ដឹងពីប្រភេទសម្ភារដែលអាចប្រើបាន ។ ការបិទប្រកាសផ្សាយដំណឹង និងស្បៀវភៅស្តើងៗ អាចជួយយុវជនឱ្យចាប់ផ្តើមស្វែងរកទីផ្សារពលកម្ម។ ជាការភ្ជាក់ផ្អើលរឿងដែលយុវជនយល់ដឹងស្តីពីសិទ្ធិហើយចេះការការពារផលប្រយោជន៍របស់គេ ។

ជាលំដាប់លំដោយគេនិយាយអំពីជីវិតផ្ទាល់របស់គេ និងសកម្មភាពផ្សេងៗ ក្នុងនោះគេបានចូលរួមចំណែក, ពន្យល់អំពីភាពខុសគ្នារវាងជីវិតរបស់គេ និងរបស់កុមារពលកម្ម ។ យើងត្រូវសង្ឃឹមថា, បុគ្គលក្នុងក្រុមរបស់អ្នកអាចសប្បាយក្នុងជីវិតរបស់គេ-តាមរយៈកីឡា, ល្បែងកំសាន្ត, សាលារៀន, មិត្តភក្តិ និងគ្រួសាររបស់គេ ។ យើងត្រូវសង្ឃឹមថា, គេ អាចសប្បាយរីករាយ មានការចម្រើនឡើងផ្នែករៀនសូត្រអំពីទិដ្ឋភាពផ្សេងៗ នៃជីវិត រៀនសូត្រដើម្បីក្លាយជាសមាជិកក្រុមម្នាក់, សហគមន៍មួយ, សង្គមមួយ ។ រៀនសូត្រឱ្យដឹងថាយើងទាំងអស់គ្នា ពិតជាប្រជាជននៃពិភពលោក ។

ត្រូវបង្ហាញឱ្យឃើញជាក់ស្តែងថា កុមារធ្វើការងារ មិនមានការសប្បាយរីករាយឡើយ ។ ការខ្វះទិដ្ឋភាព ទាំងនេះក្នុងជីវិតរបស់គេ, មានន័យថាកុមារទាំងនោះ"បាត់បង់កុមារភាព" ។

សួរទៅក្រុមថាតើគេឃើញអ្វីជាមូលដ្ឋានផ្សេងៗគ្នារវាងខ្លួនគេ និងកុមារធ្វើពលកម្ម ។ ដោយសង្ឃឹមថា, យ៉ាងហោចណាស់មនុស្សម្នាក់ នឹងធ្វើអត្តសញ្ញាណកម្មនេះដូចជា"សើរភាពនៃការជ្រើសរើស" ។

ការពិតពួកគេអាចត្រូវបានជំរុញដោយឪពុកម្តាយ និងគ្រួសារ ដោយសេចក្តីត្រូវការរបស់បុគ្គលក៏ដូចជា ស្ថានភាពសេដ្ឋកិច្ច ។ ប៉ុន្តែនេះជាជម្រើសមួយដែលគេធ្វើ ហើយគ្មាននរណាម្នាក់មកបង្ខំឱ្យធ្វើការជ្រើសរើសនេះឡើយ។ គេប្រហែលជារស់នៅជាមួយគ្រួសាររបស់គេ, បានទទួលការអប់រំ និងមានពេលលេងល្បែងសប្បាយរីករាយក្នុងកុមារភាពរបស់គេ ។ ភាគច្រើននៃកុមារដែលធ្វើការងារពុំមានលទ្ធភាពនេះទេ ។

ក្នុងការតាមដានការពិភាក្សានេះ,គេអាចដឹង និងស្គាល់សិទ្ធិផ្ទាល់របស់គេក្នុងប្រទេស ។ ត្រូវរៀបចំការប្រជុំនេះឱ្យទៅជាការបំផុសគំនិត ។ សូមសួរទៅក្រុម តើគេស្គាល់អ្វីខ្លះអំពីសិទ្ធិជាក់លាក់របស់គេ និងកត់ត្រាចម្លើយ របស់គេនៅលើក្តារខៀនឬលើក្រដាសផ្ទាំងធំ ។ សួរអំពីម៉ោងធ្វើការងារអតិបរិមា,ការកំណត់អាយុ,ថ្លៃឈ្នួលអប្បបរមា,ការងារពេលព្រឹកព្រលឹម

និងពេលយប់, ការសម្រាកចេញលេង ក្នុងករណីយកិច្ចរបស់និយោជក ។ រឿងដែលសំខាន់ណាស់គឺ IPEC ចាប់ផ្តើមចុះបញ្ជីការគាំទ្ររបស់យុវជនក្មេងៗនៅក្នុងពិភពលោកក្នុងយុទ្ធនាការលុបបំបាត់ពលកម្មកុមារ និងការពារសិទ្ធិទូទៅរបស់កុមារ, យុវជនក្នុងជាតិផ្សេងៗ ។ នេះជាផ្នែកមួយសំខាន់សម្រាប់ទ្រទ្រង់ ដំណើរការនៃគរុកោសល្យ គួរតែស្រាវជ្រាវផ្នែកនេះជាអាទិភាព ដើម្បីអនុវត្តម៉ូឌុលនេះ និងមានមូលដ្ឋានព័តិមានអំពីបញ្ហាទាំងនេះនៅក្នុងដៃរបស់អ្នក ។

ប្រសិនបើអ្នកមានសម្ភារដែលអាចប្រើប្រាស់បាន ចូរបញ្ជូនសម្ភារៈនោះឱ្យធ្វើចរាចរក្នុងចំណោមសិស្សរបស់គេ និងរកឱ្យឃើញទីកន្លែងដែលសមស្របនៅក្នុងបន្ទប់រៀនដើម្បីបិទប្រកាសព័តិមានទាំងនេះ។ លើកទឹកចិត្តក្រុមយុវជនឱ្យអានប្រកាសនេះ ។ យុវជនគួរដឹងអំពីសិទ្ធិរបស់គេ និងមិនត្រូវភ័យខ្លាច ហើយក្រោកឈរឡើងដើម្បីការពារសិទ្ធិរបស់គេ។ កុមារពលកម្មទាំងនោះជួនកាលមិនស្គាល់សិទ្ធិរបស់គេទេ។ គេអាចមិនចេះអាន ឬសរសេរ និងគ្មាននរណានិយាយប្រាប់គេអំពីសិទ្ធិរបស់គេឡើយ។ គ្មាននិយោជកណា ដែលធ្វើការនៅក្បែរៗកុមារមិនដឹងថាការប្រើប្រាស់កុមារខុសច្បាប់នោះឡើយ។ អំពើខុសច្បាប់នេះចេះតែកើតមានជានិច្ច។ ហេតុអ្វីបានមានការខុសច្បាប់នេះ? ចំពោះរឿងនេះការអប់រំ គឺជាកត្តាកំណត់សម្រាប់រាល់អ្នកគ្រប់គ្រងកុមារ, ឪពុកម្តាយ, និយោជក និងអាជ្ញាធរ ។

ការវាយតម្លៃ និងសកម្មភាពបន្ត



មានលទ្ធផលជាក់លាក់មួយចំនួនដែលពាក់ព័ន្ធនឹងភារកិច្ចដែលត្រូវតែទទួលនឹងការគាំទ្រមួយចំនួន ព្រមទាំងព័តិមានបានមកពីប្រភពខាងក្រៅ ។ ទោះជាយ៉ាងណាក៏ដោយទិដ្ឋភាពទាំងអស់នេះ មិនអាចវាស់វែងបានដោយងាយៗទេក្នុងរយៈពេលខ្លី ។ នេះគឺជាការរីកចម្រើនរបស់បុគ្គលតែប៉ុណ្ណោះ ក្នុងម៉ូឌុលទាំងឡាយជាបន្តបន្ទាប់ ដែលអ្នក នឹងមានគំនិតខ្លះអំពីលទ្ធផលជោគជ័យនៃម៉ូឌុលពិសេសនេះ ។

ម៉ូឌុលនេះអាចមានប្រសិទ្ធិភាពបំផុត ហើយត្រូវបានចាត់ទុកជាគ្រឹះសម្រាប់ម៉ូឌុលផ្សេងទៀត។ ម៉ូឌុលនេះគឺជាផ្នែកសំខាន់មួយ នៃដំណើរការរៀនសូត្រហើយវានឹងធ្វើឱ្យប្រសើរថែមទៀត នូវចំណេះដឹងពីមុនមក ស្តីអំពីពលកម្មកុមារ ។ហេតុនេះបើគ្មាន

ម៉ូឌុលនេះជាជំនួយទេនោះ ការអនុវត្តគម្រោងមានការរីកចម្រើនតិចតួច។ ដូច្នេះ ប្រសិនបើម៉ូឌុលនេះចេញផ្សព្វផ្សាយទាន់ពេលលុះត្រាតែមានការព្យាយាមឡើង។ សូម កុំបង្រៀនដោយប្រើរយៈពេលវែងពេក ហើយត្រូវធ្វើឱ្យមានការឆ្លាស់គ្នាសកម្មភាព ពិបាកៗ និងសកម្មភាពស្រាលៗ។

នៅពេលដែលអ្នកបានបញ្ចប់ម៉ូឌុលនេះ, អ្នកឆ្លងទៅកាន់ម៉ូឌុល សន្ទនា និង អង្កេត ។ ម៉ូឌុលទាំងពីរនេះបញ្ចូលគ្នាផ្តល់នូវវេទិកាដ៏ធំទូលាយមួយនៅទីនោះ យុវជន អាចពង្រីកមនសិការរបស់គេឱ្យរីកធំឡើង និង ធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់គេ ជាភ្នាក់ងារដែលធ្វើឱ្យសង្គមប្រែប្រួល ។

ឧបសម្ព័ន្ធ ១

ទិបសាយដែលផ្តល់ព័ត៌មានពលកម្មកុមារ

ឈ្មោះអង្គការ	អាស័យដ្ឋានទិបសាយ	ជីវប្រវត្តិសង្ខេប
កម្មវិធីអន្តរជាតិដើម្បីបំបាត់ពលកម្ម(IPEC)	www.ilo.org/public/english/90ipec /index.html	តាំងពីដើមទសវត្សរ៍ឆ្នាំ ៩0,អង្គការ ពលកម្មអន្តរជាតិ(ILO) បានវាយប្រហារយ៉ាងខ្លាំង ប្រឆាំងពលកម្មកុមារ តាមរយៈកម្មវិធី IPEC ដោយជួយប្រទេសជាសមាជិកក្នុងការអនុវត្តន៍នយោបាយជាតិ និងកម្មវិធីដោះស្រាយបញ្ហាពលកម្មកុមារ ។
មូលនិធិសហប្រជាជាតិសម្រាប់កុមារ (យូនីសេស្វ)	www.unicef.org	យូនីសេស្វដែលជាអង្គការរបស់សហប្រជាជាតិគិតគូរអំពីបញ្ហាដែលទាក់ទងនឹងកុមារ ។ពលកម្មកុមារមានលក្ខណៈពិសេសនិងសំខាន់ក្នុងចំណោមសកម្មភាពរបស់ខ្លួន ។ គេធ្វើសហប្រត្តិបត្តិការយ៉ាងជិតសិទ្ធិជាមួយ IPEC ។
ប្រឆាំងនឹងសង្គមទាសភាព	www.anti.slaverysociety.org	អង្គការក្រៅរដ្ឋាភិបាលដែលប្រយុទ្ធប្រឆាំងនឹងទាសភាពមានព័ត៌មានជាច្រើនទំព័រស្តីពីបណ្តាញប្រល័យពូជសាសន៏ ។ត្រូវផ្តល់ដល់និស្សិតនិងគ្រូបង្រៀននូវធនធាន និងចំណងទាក់ទងគ្នា។
ដំណើរការពិភពលោកប្រឆាំងនឹងពលកម្មកុមារ	www.globalmarch.org	ទិបសាយរបស់អ្នក រៀបចំជាផ្លូវការនូវដំណើររបស់ពិភពលោកឆ្នាំ ១៩៩៨ មានព័ត៌មានលម្អិតអំពីដំណើរការក្នុងពិភពលោកទាំងមូល ព័ត៌មានខ្លី១ស្តីពីពលកម្មកុមារ និងចំណងទាក់ទងជាមួយអង្គការទាំងឡាយដែលពាក់ព័ន្ធ ។
សហព័ន្ធអន្តរជាតិនៃសំណង់ និងអ្នកធ្វើការងារអំពីឈើ (IFBWW)	www.ifbww.org	អង្គការសហព័ន្ធអន្តរជាតិដែលធ្វើឱ្យមានដំណើរយុទ្ធនាការពិភពលោកដើម្បីលុបបំបាត់ពលកម្មកុមារក្នុងផ្នែកសំណង់រោងចក្រ ។

ឈ្មោះអង្គការ	អាស័យដ្ឋានគិបសាយ	ជីវប្រវត្តិសង្ខេប
អប់រំអន្តរជាតិ (EI)	www.ei.ie.org	អង្គការសហព័ន្ធគ្រូបង្រៀនអន្តរជាតិ តម្រង់ទិសគ្រូបង្រៀនឱ្យយុទ្ធនាការប្រឆាំងពលកម្មកុមារ និងកសាង សម្ភារគរុកោសល្យ ។
បណ្តាញសហព័ន្ធអន្តរជាតិ (UNI)	www.union.network.org	អង្គការសហជីពអន្តរជាតិសម្រាប់សេវាកម្មតំបន់ដែលបង្កើតយុទ្ធនាការប្រឆាំងពលកម្មកុមារជាពិសេសផ្នែកពាណិជ្ជកម្មអន្តរជាតិ ។
សហព័ន្ធអន្តរជាតិនៃសហជីពសេរី(ICFTU)	www.icftu.org	អង្គការសហព័ន្ធអន្តរជាតិសម្រាប់មជ្ឈមណ្ឌលសហជីពដែលចូលរួមក្នុងយុទ្ធនាការអន្តរជាតិរបស់សហជីពដើម្បីលុបបំបាត់ពលកម្មកុមារ ។
សហគមន៍អន្តរជាតិនៃម្ហូបអាហារ,កសិកម្ម, សណ្ឋាគារ,ភោជនីយដ្ឋាន ថ្នាំជក់និងសមាគមន៍សម័ន្ធពលករ(IUF)	www.iuf.org	អង្គការសហជីពអន្តរជាតិដឹកនាំយុទ្ធនាការរបស់ខ្លួនជ ាពិសេសក្នុងអាជីវកម្មសំខាន់ៗ ការដាំដុះ និងកម្មករដាំដុះ ។
សេវាកម្មសាធារណៈអន្តរជាតិ(PSI)	www.world.psi.org	អង្គការសហជីពអន្តរជាតិសម្រាប់កម្មករសាធារណៈដែលបច្ចុប្បន្នកំពុងដឹកនាំយុទ្ធនាការមួយដើម្បីទប់ស្កាត់ការប្រើប្រាស់ឧបករណ៍វះកាត់ផលិតដោយកុមារក្នុងមន្ទីរពេទ្យសាធារណៈ ។
ផ្តល់សេរីភាពចំពោះការរំដោះកុមារឱ្យមានសេរីភាព	www.freethechildren.org	សប្បុរសធម៌របស់សហរដ្ឋអាមេរិកជាមួយនឹងកម្មវិធីនិងសកម្មភាពកាត់បន្ថយភាពក្រីក្រ និងអាជីវកម្មកុមារទូទាំងពិភពលោក ។
ពិភពលោកមានតែមួយ	www.oneworld.net	ពិភពលោកតែមួយ គឺជាសហគមន៍មួយមានអង្គការជាង ២៥០ ដែលពាក់ព័ន្ធនឹងយុត្តិធម៌សង្គម បញ្ហាមនុស្សធម៌-សិទ្ធិកុមារ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ជីវប្រវត្តិសង្ខេប
អាំនីសស្ទីនអន្តរជាតិ	www.amnesty.org	អង្គការអន្តរជាតិសម្រាប់ការពារសិទ្ធមនុស្សក្នុងទូទាំងពិភពលោក ។
បណ្តាញព័ត៌មានស្តីពីសិទ្ធិកុមារ	www.crin.org	បណ្តាញពិភពលោកនៃអង្គការបែងចែកបទពិសោធន៍ និងព័ត៌មានអំពីសិទ្ធិកុមារ ។
សម័ន្ធភាពពិភពលោក	www.ymcas.int	ចលនាពិភពលោកទាក់ទងនឹងពិភពលោក អំពីអាជីវកម្មកុមារទោះជាក្នុងរូបភាពណាក៏ដោយ ។ សង្គមជាតិរបស់គេបានចុះកិច្ចសន្យាក្នុងសកម្មភាពប្រយុទ្ធប្រឆាំងនឹងបាតុភូតនេះ ។
សមាគមន៍ស្ត្រីអន្តរជាតិនៃប៉ែក-ប៉ាស៊ីហ្វិកនិងអាស៊ីភាគអាគ្នេយ៍	www.ppseawa.org	សមាគមន៍ស្ត្រីអន្តរជាតិបានចូលរួមក្នុងសកម្មភាព ផ្សព្វផ្សាយសន្តិភាព និងលើកកម្ពស់យល់ដឹងរបស់តំបន់នេះនៃពិភពលោក ។ ធនធានរបស់គេគឺបរិច្ចាកចំពោះសុខមាលភាពស្ត្រី និងកុមារ ។
(Sweatshop Watch)	www.sweatshopwatch.org	ស្វីតហ្សបវច្ច: គឺជាអង្គការមួយក្រុមនិងបុគ្គល ដែលបានធ្វើការ ដើម្បីលុបបំបាត់ ការធ្វើអាជីវកម្មក្នុងរោងជាង។ ការងាររបស់គេមានអប់រំសាធារណៈ ការគាំទ្រ ការទាមទារសាធារណៈ និងរួមគ្នា ។
CaSa Allianza- convenant House America	www.CaSaalianza.org	អង្គការក្រៅរដ្ឋាភិបាលការពារកុមារតាមចិញ្ចើមថ្នល់ក្នុងប្រទេសកាតេម៉ាឡេ,ហុងឌុយរាស និងម៉ិកស៊ីកូ។ វាជាសាខាអាមេរិកឡាទីនរបស់ Canvenant House ដែលមានមូលដ្ឋាននៅសហរដ្ឋ ។
កីឡាអាល់ប៊ែតាប៉ាគីស្តាន	www.alberta.sports.com	អ្នកផលិតបាល់ទាត់មានមូលដ្ឋាននៅស៊ីអាល់កុត, ប៉ាគីស្តាន,ដែលជាផ្នែករបស់កម្មវិធី ILO ដើម្បីលុបបំបាត់ពលកម្មកុមារក្នុងរោងចក្រ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ជីវប្រវត្តិសង្ខេប
ប្រព័ន្ធព័ត៌មានឈ្មោះថា គំនិតថ្មី	www.newconceptinfo.com	ក្រុមវិជ្ជាជីវៈក្នុងប្រទេសឥណ្ឌាដែលផ្តល់ការស្រាវជ្រាវ និងផ្សព្វផ្សាយសេវាកម្ម, អភិវឌ្ឍន៍សង្គម រួមមាន សេវាកម្មពលកម្មកុមារ ។
ការពារកុមារអន្តរជាតិ (DCI)	www.defence-for-children.org	អង្គការក្រៅរដ្ឋាភិបាលផ្សព្វផ្សាយ និងការពារសិទ្ធិកុ មារ សាខាមានទូទាំងពិភពលោក ។
CAFOD	www.cafod.org.UK	CAFOD គឺជាភ្នាក់ងារផ្តល់ការជួយ និងអភិវឌ្ឍនិវិហារ កាតូលិកក្នុងប្រទេសអង់គ្លេស, អង្គការនេះគាំទ្រយុទ្ធនា ការសំខាន់មួយប្រឆាំងនឹងពលកម្មកុមារក្នុងឧស្សាហកម្ម សម្លៀកបំពាក់ ។
សំណាញ់បៃតង	www.gn.apc.org	សំណាញ់បៃតង គឺជាផ្នែកមួយនៃបណ្តាញកុំព្យូទ័រពិភព លោកដើម្បីបរិស្ថាន, សិទ្ធិមនុស្ស និងអភិវឌ្ឍន៍ក្រុម ។ សមាជិកចំនួន ២00 មានទីកន្លែងនៅសំណាញ់បៃតង
ក្រុមធនាគារពិភពលោក	www.worldbank.org	វែបសាយសម្រាប់ធនាគារពិភពលោកដែលពាក់ព័ន្ធការ អភិវឌ្ឍន៍/ស្ថាប័នហិរញ្ញវត្ថុ
ព័ត៌មានសំខាន់	www.essential.org	ព័ត៌មានសំខាន់ គឺជាបណ្តាញអង្គការដែលផ្តោត លើការអភិវឌ្ឍន៍ និងបញ្ហាមនុស្សធម៌ ។
Agencia de Noticia dos Direitos da Infancia(ANDI) ទីភ្នាក់ងារសារព័ត៌មាន	www.andi.org.br	ទីភ្នាក់ងារសារព័ត៌មាននៃជនជាតិប្រេស៊ីលនិយាយអំពី បញ្ហាសិទ្ធិកុមារ
Labors of love Project គំរោងស្តីពីពលកម្មកុមារ	www.childlabor.org	អង្គការក្រៅរដ្ឋាភិបាលចែកចាយព័ត៌មានអំពីពលកម្ម កុមារជាមួយនឹងគោលដៅបញ្ចុះបញ្ចូលប្រជាជនឱ្យធ្វើ ការជាមួយគ្នាប្រកបដោយប្រសិទ្ធិភាព។ ដើម្បីបញ្ចប់ បញ្ហាពលកម្មកុមារ ជំរុញឱ្យមានការបណ្តុះបណ្តាលសម ស្រប និងការអប់រំសម្រាប់កុមារ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ជីវប្រវត្តិសង្ខេប
ផ្ទះរបស់កុមារ	www.child-abuse.com/childhouse/	មជ្ឈមណ្ឌលធនធានអន្តរកម្មសម្រាប់ផ្លាស់ប្តូរព័ត៌មានដែលបម្រើឱ្យសុខភាពកុមារ
ជំនួយគ្រឹះស្ថាន	www.christian.aid.org.uk	ទីភ្នាក់ងារផ្លូវការនៃព្រះវិហារចំនួន ៤៨ នៅក្នុងប្រទេសអ៊ៀកឡង់ដ៏។ ទីភ្នាក់ងារនេះស្រាវជ្រាវនិងប្រយុទ្ធការចាក់ឫស នៃភាពក្រីក្រ។
សហប្រតិបត្តិការណ៍អាមេរិកកាំង	www.coopamerica.org	អង្គការក្រៅរដ្ឋាភិបាលអាមេរិកាំងមានទិសដៅផ្តល់យុទ្ធសាស្ត្រសេដ្ឋកិច្ច ដើម្បីរៀបចំអំណាច និងឧបករណ៍ប្រើប្រាស់សម្រាប់ការធ្វើជំនួញ និងបណ្តុះបណ្តាលបុគ្គលសម្រាប់ដោះស្រាយបញ្ហាសង្គម និងបរិស្ថាន។
ការប្តូរបណ្តាញ	www.changenet.sk	សហគមន៍គុណធម៌នៃប្រទេសស្លូវ៉ាគី-អង្គការក្រៅរដ្ឋាភិបាលកំពុងប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាននិងធន ធាន។
ដីរបស់មនុស្ស	www.tdh.geneve.ch	អង្គការសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីសធ្វើសកម្មភាពដើម្បីបញ្ចប់ព្រឹត្តិការណ៍នៅក្រុងហ្ស៊ីរ៉ែណវ ។
សកម្មភាពអភិវឌ្ឍន៍បរិស្ថានក្នុងតតីយលោក (enda)	www.enda.sn	អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមានមូលដ្ឋាននៅទីក្រុងដាកា, សេណេហ្គាល, ពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ក្នុងតតីយប្រទេសចំនួន ៣
សង្គ្រោះកុមារ	www.oneworld.org/scf/	សមាគមន៍សំខាន់ៗនៃសប្បុរសធម៌អន្តរជាតិ
ACTIONAID	www.actionaid.org	សង្គមមានសប្បុរសធម៌និងមានការអភិវឌ្ឍន៍ដែលធ្វើការផ្តាល់ជាមួយប្រជាជនក្រីក្របំផុតជាងបីលាននាក់លើពិភពលោក(មានប្រជាជនក្នុងទ្វីបអាហ្វ្រិក,អាស៊ីនិងអាមេរិកឡាទីន)ដោយដែលជួយពួកគេក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ជីវប្រវត្តិសង្ខេប
សកម្មភាពដើម្បីសាមគ្គីភាព,សមភាព,បរិស្ថាន និងការអភិវឌ្ឍន៍	www.antenna.nl	បណ្តាញយុវជន ពិភពលោកផ្តោតលើបញ្ហាបរិស្ថាន និងការអភិវឌ្ឍន៍ ។
Corporate Watch	www.corpwatch.org	ទស្សនាវដ្តី និងមជ្ឈមណ្ឌលធនធានកំពុងគិតគូរអំពីគណៈនេយ្យសមាគមន៍ និងយុត្តិធម៌ទូទាំងពិភពលោក សង្គម និងបរិយាកាស ។
កុមារធ្វើការងារនៅទ្វីបអាស៊ី	www.cwa.tnet.co.th	CWA គឺជាបណ្តាញអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលដែលបានចលនាប្រឆាំងនឹងពលកម្មកុមារក្នុងប្រទេសផ្សេងៗនៃទ្វីបអាស៊ី ។ មានការទំនាក់ទំនង ជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសប៉ាគីស្តាន,បង់ក្លាដែស,នេប៉ាល់,ឥណ្ឌា,ឡាវ,ថៃ,ម៉ាឡេស៊ី,ឥណ្ឌូនេស៊ី ហ្វីលីពីន និងហុងកុង ។
ទីប្រឹក្សាទ្វីបអឺរ៉ុប Council of Europe	www.coe.fr	កន្លែងនេះមានអត្ថបទស្តីពីអនុសាសន៍នានាដំណោះស្រាយ និងការផ្សាយព័ត៌មានកាសែត នៃក្រុមប្រឹក្សាទ្វីបអឺរ៉ុបផ្នែកខាងក្នុង ការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ។
Echange mondial	www.globaleexchange.org	Echange mondial គឺជាមជ្ឈមណ្ឌលស្រាវជ្រាវនៃការអប់រំ និងសកម្មភាពដែលមានបំណងមិនយកកម្រៃ ។ គេធ្វើការដើម្បីយុត្តិធម៌មិនយោបាយ, សេដ្ឋកិច្ច និងសង្គមក្នុងកម្រិតពិភពលោក ។ វាមានទីសដៅបង្កើនមនសិការពិភពលោកក្នុងចំណោមសាធារណៈជន ។ សហរដ្ឋអាមេរិក និងចលនាគេ ឱ្យធ្វើសកម្មភាពកសាងដៃគូជាតិនិងអន្តរជាតិជុំវិញ ពិភពលោក ។
ទីស្តីការសម្រាប់ការអភិវឌ្ឍន៍ជាអន្តរជាតិ (DFID)	www.dfid.gov.UK	ទីស្តីការរដ្ឋាភិបាលទាក់ទងនឹងបញ្ហាអភិវឌ្ឍន៍ក្នុងនោះមានពលកម្មកុមារ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ពិពណ៌នាសង្ខេប
ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ (USAID)	www.usaid.gov	USAIDគឺជាភ្នាក់ងាររដ្ឋាភិបាលឯករាជ្យរបស់សហរដ្ឋអាមេរិកដែលនាំមកនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជំនួយមនុស្សធម៌ដើម្បីផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចនយោបាយសហរដ្ឋអាមេរិកនៅឯនាយសមុទ្រ ។
ទីស្តីការក្រសួងការងារ,រដ្ឋាភិបាលសហរដ្ឋអាមេរិក	www.dol.gov	ទីស្តីការទទួលបន្ទុករៀបចំហត្ថពលអាមេរិកាំងដើម្បីធ្វើការងារថ្មីកាន់តែប្រសើរឡើងនិងរ៉ាប់រងឱ្យបានល្អទីកន្លែងធ្វើការរបស់អាមេរិក ។
ការស្ថាបនាអន្តរជាតិ	www.rugmark.de	ការស្ថាបនាអន្តរជាតិ គឺជាផ្លាកនៃពាណិជ្ជកម្មដ៏ត្រឹមត្រូវផ្តល់ឱ្យ អ្នកផលិតកម្រាលព្រំ និងភួយដែលគោរពច្បាប់ដឹកនាំរបស់អ្នកស្ថាបនាអន្តរជាតិ ។
សមាគមអាមេរិកកាំងសម្រាប់ អ្នកធ្វើការនៅជនបទ	www.afop.org	ទីកន្លែងនេះមានយុទ្ធនាការរបស់ AFOP ដើម្បីលុបបំបាត់ពលកម្មកុមារចេញពីការងារកសិកម្មនៅសហរដ្ឋអាមេរិក។
សម្ព័ន្ធជាតិសម្រាប់អ្នកប្រើប្រាស់(NCL) សហដ្ឋេអាមេរិក។	www.nclnet.com	ក្នុងចំណោមអង្គការអ្នកប្រើប្រាស់ដ៏ធំមួយ ដែលមានការទំនាក់ទំនងឯជាមួយការងាររបស់កុមារក៏ដូចជានយោបាយនិងកម្មវិធីផ្ទាល់របស់គេ ។
UNITE!	www.uniteunion.org	សមាគមវាយនភ័ណ្ឌនិងកម្មករកាត់ដេរសម្លៀកបំពាក់នៅសហរដ្ឋាអាមេរិក ដែលបានព័ត៌មានស្តីពីពលកម្មកុមារ ។ សហគមន៍នេះ រៀបចំឱ្យមានចំណងទាក់ទងមួយចំនួនពិសេសកន្លែងធ្វើការរបស់សហជីពផ្សេងៗទៀត ។
កម្មវិធីអន្តរជាតិសម្រាប់យុវជន (YAPI)	www.yapi.org	កន្លែងដែលមានបញ្ហាដ៏ច្រើនសម្រាប់យុវជន ។ អង្គការមួយចំនួនកំពុងដោះស្រាយបញ្ហាទាំងនេះដោយផ្ទាល់ខ្លួនទូទាំង ពិភពលោក ។
ខនសឺន សម្រាប់កុមារធ្វើការងារ	www.workingchild.org	កន្លែងនេះផ្តល់តែព័ត៌មានដែលពាក់ព័ន្ធទៅនឹងពលកម្មកុមារ ។

ឈ្មោះអង្គការ	អាស័យដ្ឋានវិបសាយ	ជីវប្រវត្តិសង្ខេប
សហភាពអឺរុប (UE)	www.europa.eu.int	វែបសាយផ្លូវការរបស់សហភាពអឺរ៉ុប (UE) ។ ផ្តល់ការទំនាក់ទំនងដ៏ធំចំពោះអ្នកចូលសមាគមក៏ដូចជាការផ្លែងការណ៍នយោបាយ និងទំនាក់ទំនងទីស្តីការជាមួយនឹងគណៈកម្មការ ។
សម័ន្ធអន្តរជាតិដើម្បីសង្គ្រោះកុមារ	www.savechildren.org.jp	មិនមែនជាកន្លែងល្អប្រសើរសម្រាប់សង្គ្រោះកុមារនោះទេ, ប៉ុន្តែវាផ្តល់នូវចំណងទាក់ទងនឹងជាតិដ៏ល្អិតល្អន់ ហើយជាចំណុចចាប់ផ្តើមនៃសកម្មភាពប្រកបដោយគុណភាពការងារល្អស្តីពីពលកម្មកុមារដែលអង្គការនេះបានបំពេញរួចមកហើយ ។
Levis Strauss & co.	www.levistrauss.com	វែបសាយផ្លូវការនៃពហុជាតិ មានផ្នែកមួយពាក់ព័ន្ធទៅនឹងកម្មវិធីសហគមន៍របស់ខ្លួននិងផ្តល់អាហារូបករណ៍សិក្សា ។ គម្រោងមូលនិធិក្រុមហ៊ុនក្នុងផ្នែកមួយចំនួន, មានយុត្តិធម៌សង្គមជាដើម ។
Reebok	www.reebok.com	Reebok មានបោះពុម្ពផ្សាយសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សក្នុងវែបសាយរបស់ខ្លួន ។ គេអះអាងអំពីគុណប្រយោជន៍នៃពាណិជ្ជកម្មត្រឹមត្រូវ និងលក្ខខ័ណ្ឌការងារល្អប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ។
Clean Clothes Campaign	www.cleanclothes.org	The clean Clothes Campaign (CCC) មានគោលបំណងធ្វើឱ្យលក្ខខ័ណ្ឌការងារប្រសើរឡើងនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់កីឡា ។ ទិសដៅសំខាន់របស់គេ គឺឆ្ពោះទៅរកអ្នកលក់រាយដែលលក់ផលិតផល ផលិតដោយកុមារ ។

គណៈកម្មការដឹកនាំ និងគ្រប់គ្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គូច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការរៀបរៀង និងចងក្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គូច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៦_លោក ឡង់ សុផាត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការបកប្រែ

១_លោកស្រី កង សុថាវី	ប្រធានការិយាល័យក្រោយអក្ខរកម្ម	២_លោកស្រី តុប ប៊ុនថា	ប្រធានការិយាល័យអក្ខរកម្ម
៣_លោក ព្ញ៉ែម ភីណារ៉ែត	អនុប្រធានការិយាល័យរដ្ឋបាល	៤_លោក តេះ ដារី	អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ
៥_លោក ជិន និវត្តន៍	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_លោកស្រី ទី វត្តី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោក ភូ យន់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៨_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៩_កញ្ញា អ៊ុក ធារី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	១០_លោក គ្រួច លក្ខិណា	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
១១_លោកស្រី លី ខេង	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការផ្ទៀងផ្ទាត់

១_លោក សំ ចាន់ទិត	អនុប្រធានការិយាល័យអក្ខរកម្ម	២_លោក រង់ សូវង្ស	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក ឈុំ ច័ន្ទមុនីរ៉ែត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៤_លោកស្រី ជា សុផល	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក កែវ គង់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_កញ្ញា ម៉ៅ ផល្លី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

១_លោក ឈិន វិត	ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
២_លោក ពេជ្រ និពន្ធ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៣_លោកស្រី ឈុំ សោភ័ណ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៤_លោកស្រី សួច ផាន់ណា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៥_លោកស្រី ទី វ៉ាដា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៦_កញ្ញា សន សុម៉ាលី	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

✕ បញ្ឈប់ពលកម្មកុមារ

Stop Child Labour

Supporting Children's Rights through Education, the Arts and the Media (SCREAM)

សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេឆណារ៉ាវី ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្ក្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨

Email : nfe@camnet.com.kh

ISBN-9789995088217